**មជ្ឈមណ្ឌលដើម្បី សន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំ ខប់សែលប្រ៉ម តំបន់ទី ៥

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

# ថ្ងៃសុក្រ ទី១៨ ខែសីហា ឆ្នាំ២០០៦

**ខេត្តកំពង់ឆ្នាំង**

**ខប់សែល ដំណាក់កាលទី ២**

COPCEL Phase II

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

**របៀបវារៈ**

១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក **ឡារី ស្ត្រេន្ទ (Larry Strange)** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក **ឱក សេរី សោភក្តិ៍** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោកស្រី **នួន ចាន់នី** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តកំពង់ឆ្នាំង

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទ ខេត្តកំពង់ឆ្នាំង

៥. សេចក្តីផ្សេងៗ

---

## ១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក ឡារី ស្ត្រេន្ទ (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

លោកមានសេចក្តីរីករាយណាស់ដោយបានចូលរួម និងមានឱកាសស្វាគមន៍ដល់លោក លោកស្រីនៅក្នុងកិច្ចប្រជុំថ្ងៃនេះ ជាពិសេសដល់លោកប្រធាន ខុទ្ទកាល័យខេត្ត និងលោកស្រីប្រធាន គជបខ ព្រមទាំងមានកិត្តិយសណាស់ ដោយថ្ងៃនេះ មានវត្តមានលោកប្រធាន UNDP ប្រចាំនៅកម្ពុជា ព្រមទាំងសហការី ដែលបានជួយឧបត្ថម្ភដល់យន្តការខប់សែល និងតំណាង SIDA ដែលបានផ្តល់ជំនួយដល់ វិបសអ សំរាប់កម្មវិធីអភិបាលកិច្ចតាមបែបបជាធិបតេយ្យ និងកំណែទំរង់សាធារណៈ ។ លោកបានថ្លែងអំណរគុណដល់ឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំង ដែលបានគាំទ្រ និងបានអនុញ្ញាត ឱ្យ វិបសអ រៀបចំកិច្ចប្រជុំនេះឡើង ។ ដូចលោក សោភក្តិ៍ បានជំរាបជូន យើងខ្ញុំបានចុះទៅរៀបចំកិច្ចប្រជុំបែបនេះ នៅខេត្តបន្ទាយមានជ័យ ក្រុងប៉ៃលិន ខេត្តបាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំងនៅថ្ងៃនេះ ដែលខេត្តនីមួយៗមានអ្នកចូលរួមយ៉ាងសកម្មពីសំណាក់លោក លោកស្រី ដែលពាក់ព័ន្ធនឹងការងារបោះឆ្នោតនេះ ហើយការលើកឡើងនៅក្នុងកិច្ចប្រជុំនីមួយប្រកបដោយការគោរព បើកចំហ និងដោយស្មោះត្រង់ ដើម្បីជំរុញ ឱ្យមានការពិភាក្សាប្រកបដោយផ្លែផ្កា ។

លោកបានបង្ហាញដោយសង្ខេបដល់អង្គប្រជុំថា ហេតុអ្វីបានជា វិបសអ គិតថា ខប់សែល មានសារៈសំខាន់? វិបសអ ជាស្ថាប័នស្រាវជ្រាវឯករាជ្យ អព្យាក្រិត មិនពាក់ព័ន្ធនឹងរឿងនយោបាយ ដោយសិក្សាលើការស្រាវជ្រាវពីគោលនយោបាយនានាសំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។ វិបសអ សិក្សាទៅលើ ៥ វិស័យសំខាន់ៗ ដែលមូលដ្ឋានគ្រឹះសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពដល់សេដ្ឋកិច្ចជាតិគឺ សេដ្ឋកិច្ច និងពាណិជ្ជកម្ម ការកាត់បន្ថយភាពក្រីក្រ កសិកម្មនិងការអភិវឌ្ឍន៍ជនបទ ការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនជនបទ អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់សាធារណៈ ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និងសន្តិសុខមនុស្ស ការកសាងសន្តិភាព និងការដោះស្រាយទំនាស់ ។ ក្នុងចំណោមវិស័យទាំងអស់នេះ អាចសំរេចទៅបាន គឺអាស្រ័យទៅលើកត្តាសំខាន់មួយ គឺការកែលំអអភិបាលកិច្ច ការកសាងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ឱ្យបានរឹងមាំ និងពិតប្រាកដ ប្រកបដោយប្រសិទ្ធិភាព គឺជាចំណុចមួយដែលឆ្ពោះទៅដល់ការកសាង និងការអភិវឌ្ឍន៍ប្រទេសកម្ពុជាមួយដែលរីកចំរើន ។ វិបសអ យល់ថា ការរៀបចំការបោះឆ្នោតមួយឱ្យបានជោគជ័យ និងមានប្រសិទ្ធិភាព គឺជាជំហានមួយដែលឆ្ពោះទៅរកការកសាងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ ហេតុនេះហើយបានជា ខប់សែលមានសារៈសំខាន់ណាស់សំរាប់ វិបសអ ដែលជាវេទិកាសំខាន់នៅក្នុងការចូលរួមចំណែកកសាងវប្បធម៌នៃការពិភាក្សាគ្នា ជុំវិញការងារបោះឆ្នោត ដើម្បីឱ្យមានការពិភាក្សាមួយដោយសុវត្ថិភាព និងដោយបើកចំហ ។

វេទិកានេះសំរេចទៅបាន គឺដោយសារមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសកម្ពុជាទាំងនៅថ្នាក់ជាតិ រហូតដល់ថ្នាក់ខេត្ត ដែលមានការចូលរួមពីក្រសួងមហាផ្ទៃ ក្រសួងពាក់ព័ន្ធនានា គជប តំណាងរបស់គណបក្សនយោបាយ អង្គការសង្គមស៊ីវិលនានាដែលធ្វើការពាក់ព័ន្ធនឹងការបោះឆ្នោត ឯថ្នាក់ខេត្តគឺទទួលបានការគាំទ្រពីឯកឧត្តមអភិបាលខេត្ត អាជ្ញាធរខេត្ត អង្គការសង្គមស៊ីវិលនៅក្នុងខេត្ត ពិសេសគឺតំណាងគណបក្សនយោបាយនានារួមមាន គណបក្សកាន់អំណាច គណបក្សប្រឆាំង ព្រមទាំងការចូលរួមពីសំណាក់ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងតុប្រជុំតែមួយ ដែលមានការពិភាក្សាគ្នាទៅវិញទៅមកដោយស្មោះត្រង់ ។ នេះបញ្ជាក់ពីសញ្ញាណជោគជ័យនៃការបោះឆ្នោតមួយប្រកបដោយតម្លាភាព និងត្រឹមត្រូវ ។ វបសអ មានសេចក្តីរីករាយដែលបានផ្តល់នូវការសំរបសំរួល និងលើកជាវេទិកាជូនលោក លោកស្រី នៅក្នុងការប្រជុំ ខប់សែលនីមួយៗ តែការសំរេចបាននៅក្នុងកិច្ចប្រជុំនីមួយៗ គឺអាស្រ័យលើអ្នកចូលរួមទាំងអស់ ដើម្បីលើកឡើងនូវបញ្ហាប្រឈមនានាជុំវិញការងារបោះឆ្នោតដែលជួបប្រទះក្នុងខេត្តនេះ ដូច្នេះសូមអញ្ជើញមានប្រសាសន៏ដោយចំហ និងដោយស្ថាបនា ។

ជាថ្មីម្តងទៀត លោកបានថ្លែងអំណរគុណដល់ប្រធាន UNDP និង SIDA ដែលបានចូលរួមសង្កេតក្នុងយន្តការនេះ ។

**លោក Douglas Gardner** UNDP Resident Representative and UN coordinator លោកបានបន្ថែមសេចក្តីរីករាយដែលលោកជាតំណាង UNDP និង SIDA បានមកចូលរួមជាមួយលោក លោកស្រីនាព្រឹកនេះ ក្នុងនាមជាអ្នក សង្កេតការណ៏ និងមើលឃើញពីទិដ្ឋភាពជាក់ស្តែង ។ សំរាប់ លោក លោកស្រីដែល អញ្ជើញមកពីក្រុងភ្នំពេញ បានសិក្សា និងចូលក្នុងកម្មវិធីនានាដែលបានធ្វើកន្លងមក តែអ្វីដែលសំខាន់គឺការបានមកឃើញទិដ្ឋភាពជាក់ស្តែងនៃការពិភាក្សានៅព្រឹកនេះ ។ ចំណុចមួយដែលលោកបានរួមចំណែកគឺ យើងឃើញហើយថាប្រទេសកម្ពុជាកំពុងតែមានដំណើរការវិវត្តន៏ទៅរកលទ្ធិប្រជាធិបតេយ្យតាមរយៈផែនការជាយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍន៏ប្រទេសកម្ពុជា ទាក់ទងនឹងបញ្ហានានា ដើម្បីកាត់បន្ថយភាពក្រីក្រ និងជំរុញឱ្យមានការបោះឆ្នោតមួយដែលប្រកបដោយលទ្ធិប្រជាធិបតេយ្យ ។ លោកសុំយកឱកាសនេះដើម្បីសង្កេតមើលភាពជាក់ស្តែងនៃការពិភាក្សា របស់លោក លោកស្រី ។ លោកសូមថ្លែងអំណរគុណដល់មន្ត្រីទាំងអស់ នៅខេត្តកំពង់ឆ្នាំងនេះ ដែលបានអនុញ្ញាតឱ្យ វបសអ អាចរៀបចំ និងបានចូលរួមអង្កេតក្នុងកម្មវិធីនេះ ។

## ២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក ឱក សេរី សោភ័ក្តិ៍ ទីប្រឹក្សា និងជាអ្នកសំរបសំរួល យន្តការខប់សែល នៃវិទ្យាស្ថាន CDRI

លោកបានជំរាបជូនអំពីយន្តការខប់សែលនេះ កើតឡើងនៅពេលណា ក្នុងគោលបំណងអ្វី និងបានធ្វើអ្វីខ្លះ ហើយគោលដៅក្នុងពេល ២ឆ្នាំពេលខាងមុខ សំរាប់ការបោះឆ្នោតនៅឆ្នាំ២០០៧ និង ២០០៨ ។

សង្គ្រាមបានអូសបន្លាយអស់ពេល ២៨ឆ្នាំ ហើយលោកបានរស់នៅក្នុងសង្គ្រាមនៅជាយដែនរយៈពេល ១១ឆ្នាំ យើងបានឃើញទុក្ខវេទនារបស់ពលរដ្ឋយើងត្រូវគេធ្វើបាប ។ លោកតែងគិតថា នៅពេលទទួលបានសន្តិភាព តើយើងត្រូវរក្សាសន្តិភាពនោះយ៉ាងណា? នៅពេលលោកបានមកធ្វើជានាយខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ពីឆ្នាំ១៩៩៣-១៩៩៩ លោកបានទទួលភារៈជាអ្នកទទួលរ៉ាប់រងការរៀបចំការបោះឆ្នោតដោយកម្ពុជាខ្លួនឯង ។ ដោយមានការឧបត្ថម្ភផ្នែកបច្ចេកទេសពីអង្គការ SIDA នៅឆ្នាំ១៩៩៥ បានរៀបចំកិច្ចប្រជុំធំដើម្បីព្រាងគំរោងការរៀបចំការបោះឆ្នោតឃុំ-សង្កាត់តាំងពីឆ្នាំ១៩៩៤ ដូច្នេះសូមអរគុណ SIDAដែលមានវត្តមានរបស់តំណាងនៅទីនេះស្រាប់ ។ ដោយយល់ពីបញ្ហាគន្លឹះសំរាប់គាំទ្រលទ្ធិប្រជាធិបតេយ្យ នៅពេលលោកឈប់ធ្វើការជាមួយរដ្ឋាភិបាល នៅឆ្នាំ១៩៩៩ លោកបានចូលបំរើការងារនៅ វបសអ ជាអ្នកសំរបសំរួលក្នុងកម្មវិធីសន្តិភាព និង អភិវឌ្ឍន៏ ។ នៅពេលនោះលោកបានសុំឱ្យអ្នកជំនាញការម្នាក់ ដើម្បីសិក្សាអំពីការរាលដាលទំនាស់នៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ រហូតដល់ទូរទស្សន៏ CNN បង្ហាញរូបភាព កាប់សំលាប់នានា រួមទាំងព្រះសង្ឃ ត្រូវគេធ្វើបាបធ្វើឱ្យមុខមាត់ប្រទេសកម្ពុជាធ្លាក់ចុះ ។

ហេតុនេះបានជាលោកគិតថា ហេតុអ្វីបានជាកម្ពុជាយើង កាចសាហាវម្ល៉េះ បន្ទាប់ពីរបបខ្មែរក្រហម តើទំនាស់មានប្រភពមកពីណា ។ យើងបានមើលឃើញទំនាស់មានច្រើនយ៉ាងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតទាំងអស់ ។ ទោះជាមានការទិតៀនច្រើនក៏ដោយ លោកបានសាកល្បងគិតថា ចរិត/ទំនៀមទំលាប់របស់ខ្មែរយើង គឺចូលចិត្តញញឹមដាក់គ្នាពេលនៅពីមុខគ្នា តែនៅពីក្រោយខ្នងចូលចិត្តលេងគ្នាខ្លាំងណាស់ ។ នេះហើយជាឫសគល់ពិតប្រាកដនៃទំនាស់ ។ លោកតែងស្រមៃប្រមូលតួអង្គ ទាំងអស់ក្នុងការបោះឆ្នោត មកអង្គុយជុំវិញតុជាមួយគ្នា ហើយជជែកគ្នាត្រង់ទៅត្រង់មក ។ ទោះមិនយល់ស្របគ្នានៅពេលជជែកគ្នាក៏ដោយ តែក៏យើងចាប់ផ្តើមយល់ថា ហេតុអ្វីបានជាអ្នកដទៃមិនយល់ស្របជាមួយ តើគំនិតនោះមានហេតុផលយ៉ាងណា ពេលនោះយើងចាប់ផ្តើមគោរពការខុសគ្នានោះ ទៅវិញទៅមក ហើយក៏ចាប់ផ្តើមគោរពខ្លួនឯងផងដែរ នៅពេលអង្គុយធ្វើការជិតគ្នា ទើបគំនិតដែលខុសគ្នា ខិតចូលទៅជិតគ្នា និងដោះស្រាយ គ្នាបាន ។ ហេតុនេះបានជាយន្តការខប់សែលនេះបានចាប់កំណើតឡើង ។

ដូចដែលលោក ឡារី មានប្រសាសន៍ គឺយើងយកតួអង្គដែលពាក់ព័ន្ធទាំងអស់ មកអង្គុយជិតគ្នាចំនួន ៤ឆ្នាំ ដែលមានការប្រជុំចំនួន ៥០ដងជារៀងរាល់ខែ ទោះជាជួនកាល វិបសអ ត្រូវទឹកលិចក៏ដោយ ក៏លោក លោកស្រីទាំងអស់បានមកចូលរួមមិនខកខានឡើយ ព្រោះគេយល់ថា វាជាកិច្ចការសំខាន់សំរាប់ប្រទេសជាតិ ។ យើងបានបញ្ចប់យន្តការនេះ នៅខែកញ្ញា ឆ្នាំ២០០៣ ដែលខប់សែលចាប់ផ្តើមកិច្ចប្រជុំបែបនេះលើកដំបូង នៅថ្ងៃទី ២៦ សីហា ឆ្នាំ១៩៩៩ ។ យើងបានជួយ គជប គណបក្សធំៗទាំងបី អង្គការសង្គមស៊ីវិល រហូតដល់ការបោះឆ្នោតនៅឆ្នាំ២០០២ និង ២០០៣ ។

UNDP នៅឆ្នាំ២០០៤-០៥ ជាពិសេសលោក Douglas Gardner ផ្ទាល់ បានជួបជាមួយលោក និងលោក ឡារី ដោយមានប្រសាសន៍ថា យន្តការនេះ ល្អណាស់ ជាយន្តការមួយដែលកម្ពុជាបានបង្កើត និងគូសវាសខ្លួនឯង ។ ប្រទេសទើបចាកផុតពីសង្គ្រាមកម្រធ្វើបានដោយខ្លួនឯងណាស់ ដូចនៅ East Timor ហាក់ដូចជាចង់ត្រលប់ទៅសង្គ្រាមវិញ Afganistan បានសន្តិភាពហើយ ក៏នៅតែលំបាកកសាង ចំណែកកម្ពុជាយើងបានសន្តិភាពពិតប្រាកដនៅខែធ្នូ ឆ្នាំ១៩៩៨ ពេលដែលខ្មែរក្រហមបានចូលរួមទាំងអស់ ពិសេសនៅអន្លង់វែង និងត្រពាំងប្រាសាទ ដែល តាម៉ុក ទើប បានស្លាប់ទៅក្នុងពេលថ្មីៗនេះ ។ ដូច្នេះ ៨ឆ្នាំឃើញថា ហាក់ដូចជានៅខ្លីណាស់ តែយើងបានកសាងបានច្រើនដូចនៅក្នុងបន្ទប់នេះជាដើម មានភ្លើង ម៉ាស៊ីនត្រជាក់ ផ្លូវថ្នល់ ដែលចំណាយតែ ៤ម៉ោងទៅដល់ខេត្តបាត់ដំបង ដែលពីដើមត្រូវដេកផ្លូវមួយយប់ ។ ការកសាងត្រូវចំណាយពេលវែង តែបើឈ្លោះគ្នាវិញ ខូចខាតលឿនណាស់ ។ ហេតុនេះហើយបានជាយន្តការនេះ បានសាងជាមួយគ្នានូវវប្បធម៌នៃការជជែកពិភាក្សាដោយស្មោះត្រង់ ដោយយកបញ្ហាដាក់លើតុដោយគ្មានការភ័យខ្លាច ។ ដូចនេះបានជា UNDP គាំទ្រឱ្យរៀបចំកម្មវិធីនេះឡើងវិញ ដែលលោកគិតថា យន្តការខប់សែល ដំណាក់កាលទី២ នេះ ច្រើនកើតឡើងនៅមូលដ្ឋាន បើថ្នាក់មូលដ្ឋានអាចដោះស្រាយបានទំនាស់មិនអាចរាលដល់ថ្នាក់លើទេ ។ យន្តការខប់សែល ដំណាក់កាលទី២ លែងធ្វើតែនៅថ្នាក់ជាតិទៀតហើយ ដោយឱ្យតំលៃនៅថ្នាក់មូលដ្ឋាន ដោយចុះមកធ្វើនៅថ្នាក់ខេត្ត ដោយអញ្ជើញថ្នាក់ភូមិ ឃុំ ទាំងបីគណបក្សមកចូលរួមដើម្បីនិយាយប្រាប់អង្គប្រជុំទល់មុខគ្នាថា តើនៅមានបញ្ហាណាខ្លះដែលកំពុងប្រឈម ហើយដោះស្រាយបានក៏រឺតណា រឺយ៉ាងម៉េចបាន ។ ថ្ងៃនេះយើងបានមកធ្វើនៅកំពង់ឆ្នាំង ក្រោយពីបានធ្វើនៅខេត្តកណ្តាល តាកែវ កំពត ក្រុងព្រះសីហនុ កំពង់ស្ពឺ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ដែលមានការចូលរួមយ៉ាងសស្រាក់សស្រាំ ហើយជជែកគ្នាខ្លាំងទៅខ្លាំងមក តែក្នុងឥរយាបថថ្លៃថ្នូរ គោរពគ្នា ទៅវិញទៅមក ។

ខប់សែលប្រ៊មនេះមានគោលបំណងបីធំៗ ទី១ គឺចង់ឱ្យយន្តការចុះឈ្មោះបោះឆ្នោត ក្លាយជាទំលាប់ប្រចាំថ្ងៃរបស់ពលរដ្ឋ ដែលដល់អាយុ ដូចយើងញុំាបាយបីពេលក្នុងមួយថ្ងៃដែរ យើងបានជួយ គជប ជួយលេខាធិការដ្ឋានថ្នាក់ខេត្ត ឃុំ និងធ្វើការជាមួយគណបក្សធំៗទាំងបី និង គណបក្សនានា សង្គមស៊ីវិល ។ សូមកោតសរសើរដល់សង្គមស៊ីវិលនៅកម្ពុជា ដែលកើតឡើងក្នុងរង្វង់ឆ្នាំ១៩៩៣ រហូតដល់ពេលនេះ ដែលធ្វើការបានល្អ ទាំងផ្នែកអភិវឌ្ឍន៍ សេដ្ឋកិច្ច និងអភិបាលកិច្ចល្អ ។ នេះជាមោទនភាពណាស់ដែលមានវត្តមានសង្គមស៊ីវិល ។ ទី២ គឺរាជរដ្ឋាភិបាលក្នុងផ្តល់អត្តសញ្ញាណប័ណ្ណដល់ពលរដ្ឋអាយុ ១៨ឆ្នាំ ឱ្យបានគ្រប់គ្នា ដែលលោកវារៈសេនីយតំណាងស្នងការនៅកំពង់ឆ្នាំង នឹងរាយការណ៍ជូនអង្គប្រជុំ តើកិច្ចការនេះ ដំណើរការយ៉ាងណាដែរ ខេត្តដែលយើងបានឆ្លងកាត់ធ្វើបានក្នុងចន្លោះពី ៧៦-៨៥% ។ នៅពេលខប់សែលនិយាយពីរឿងនេះ ៣ខែជាប់គ្នាគឺ តុលា វិច្ឆិកា ធ្នូ ២០០៥ ដើម្បីរំលឹករដ្ឋាភិបាលថា បញ្ហានេះ ធំណាស់ ។ ឯ.ឧ ស ខេង បានចាត់ការរឿងនេះភ្លាម ដោយបើកឆ្នាំ២០០៦

នេះជាយុទ្ធនាការគំហ៊ុកផ្តល់អត្តសញ្ញាណប័ណ្ណ ដោយសំរេចឱ្យបានដល់ខែធ្នូ ទាំង ១.៩០០.០០០នាក់ ត្រូវតែធ្វើឱ្យបាន ដើម្បីបំរើការបោះឆ្នោតឆ្នាំ២០០៧-០៨ ។ នៅពេលខប់សែលធ្វើត្រូវ រដ្ឋាភិបាលនឹងឆ្លើយតបជាវិជ្ជមាន ។

ទី៣ គឺសន្តិសុខ យន្តការបោះឆ្នោះដែលផ្អែកមួយជាគន្លឹះរបស់លទ្ធិប្រជិបតេយ្យ ឱ្យទៅជាយន្តការមួយដែលស្ងប់ស្ងាត់ ប្រកបដោយសន្តិភាព និងដែលអាចនិយាយស្តាប់គ្នាបាន ដោយមិនឱ្យមានយប់ឡើងឆ្កែព្រុះ ការគាបសង្កត់នៅតាមភូមិ ឃុំ ក៏លែងមានដែរ ដើម្បីឱ្យពលរដ្ឋគោរពស្រលាញ់ដោយទឹកចិត្តផ្ទាល់ មិនមែនឈ្នះដោយជាប់នូវស្នាមគាបសង្កត់ ដោយរើសអើងទេ ។ រាជរដ្ឋាភិបាលបានព្រមសហការក្នុងរឿងនេះ ដោយលោកបានលើកឡើងជាឧទាហរណ៍ថា ការបោះឆ្នោះលើកក្រោយលែងឱ្យមានអាជ្ញាធរមូលដ្ឋាននៅជិតស្ថានីយបោះឆ្នោតទៀតហើយ ព្រោះ គជប បានបន្ថែមមន្ត្រីរបស់ខ្លួនម្នាក់នៅខាងក្រៅស្ថានីយដើម្បីជួយពលរដ្ឋ ។ នៅពេលយើងធ្វើទៅស្តាប់គ្នាបាន អាជ្ញាធរខេត្តគ្រប់ជាន់ថ្នាក់ សហការគ្នាធ្វើគ្មានបញ្ហាអ្វីទេ ។ នេះជាគោលបំណងធំៗទាំងបី ។ ខេត្តទាំងអស់ដែលយើងបានចុះទៅ បានជជែកគ្នាខ្លាំងៗណាស់ តែស្ថិតនៅក្នុងឥរយាបថគោរពគ្នាទៅវិញទៅមក ។

## ៣. ស្ថានភាពនុះនៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោកស្រី នួន ចាន់នី ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តកំពង់ឆ្នាំង

ជាកិច្ចចាប់ផ្តើម លោកស្រីសូមគោរពភ្ញៀវកិត្តិយសទាំងអស់ ដែលមានវត្តមាននៅក្នុងអង្គប្រជុំនេះ និងសូមអរគុណដល់ វបសអ ដែលបានរៀបចំវេទិកាស្តីពីយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជាថ្នាក់ខេត្ត ។ ក្រោយកិច្ចព្រមព្រៀងថ្ងៃទី២៣ តុលា ១៩៩១ កម្ពុជាបាន ដំណើរការបោះឆ្នោតជាសាកលចំនួន ៤លើក ក្នុងនោះមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៣ លើក គឺនៅឆ្នាំ១៩៩៣, ១៩៩៨ និង ២០០៣ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០២ និងបានដំណើរការបោះឆ្នោតជាអសាកល ១លើក គឺការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី ២ នៅថ្ងៃទី២២ មករា ឆ្នាំ២០០៦ កន្លងមកថ្មីៗនេះ ។ យើងសង្កេតឃើញថា មានការបោះឆ្នោតដែលរៀបចំដោយអ៊ុនតាក់ ១លើក នៅឆ្នាំ១៩៩៣ ក្រោយមកកម្ពុជាខ្លួនឯងបានរៀបចំការបោះឆ្នោតចំនួន ៤លើក ។

ឆ្លងកាត់ការបោះឆ្នោតកន្លងមក នៅខេត្តកំពង់ឆ្នាំង តែងជួបប្រទះបញ្ហាទំនាស់ផ្សេងៗ រហូតដល់មានការប្តឹងតវ៉ាជំទាស់ជាបន្តបន្ទាប់ ទៅគ្រប់លំដាប់ថ្នាក់នៃការរៀបចំការបោះឆ្នោត ។ បណ្តឹងទាំងឡាយច្រើនកើតមានឡើង ជាពិសេសក្នុងដំណាក់កាលយុទ្ធនាការឃោសនាការបោះឆ្នោត ចន្លោះថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត និងថ្ងៃបោះឆ្នោត ។ រាល់បញ្ហានានាដែលកើតឡើង នៅអំឡុងពេលនៃដំណើរការបោះឆ្នោត ច្រើនតែចាប់បង្វែរ ឬប្រមូលផ្តុំ ឱ្យទៅជាទំនាស់រឿងនយោបាយ ហើយបាញ់ឆ្ពោះមកលើការបោះឆ្នោត ដែលរឹតតែបង្កនូវភាពស្មុគស្មាញខ្លាំងថែមទៀត ។ សំរាប់យើងទាំងអស់គ្នា អ្វីដែលកំពុងយកចិត្តទុកដាក់ គឺចង់ឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព អាចទទួលយកបាន និងគ្មានអំពើហិង្សា គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ និងប្រកបដោយលក្ខណៈប្រជាធិបតេយ្យពិតៗ ។ ដូចេះហើយបានជាពីការបោះឆ្នោតមួយទៅមួយ យើងតែងបានធ្វើការកែលំអជាបណ្តើរៗ ។ អនុវត្តន៍តាមច្បាប់បោះឆ្នោតស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងការណែនាំផ្ទាល់របស់ គជប យើងបានដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ដែលបានអនុវត្តតាំងពីឆ្នាំ២០០៤ តាមរយៈ គជប ធ្វើប្រតិភូកម្មអំណាចឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ សំដៅធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ចាប់ពីថ្ងៃ ១ តុលា ដល់ ថ្ងៃ ៣១ ធ្នូ ។ ក្នុងនោះការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅតាមបណ្តាឃុំ មានរយៈពេលតែ ១៨-២០ថ្ងៃប៉ុណ្ណោះ ដែលប្រព្រឹត្តទៅនៅដើមខែតុលាជា រៀងរាល់ឆ្នាំ ។ ដើម្បីបង្កលក្ខណៈឱ្យពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតហើយ អញ្ជើញមកពិនិត្យឈ្មោះក្នុងបញ្ជីបោះឆ្នោតឡើងវិញ ។ ក្នុងករណីពិនិត្យឃើញថា មានសរសេរឈ្មោះខុស ឬខុសទិន្នន័យនៅក្នុងបញ្ជីឈ្មោះ ដោយផ្អែកលើឯកសារបញ្ជាក់អត្តសញ្ញាណជាផ្លូវការណាមួយ ត្រូវទៅកែតំរូវឈ្មោះជាមួយស្មៀនឃុំ ជាមួយក្រុមប្រឹក្សាឃុំ ដែលដំណើរការពិនិត្យការចុះឈ្មោះបោះឆ្នោត ។

ចំណុចនេះលេខាធិការដ្ឋានសង្កេតឃើញថា ការពិនិត្យឈ្មោះ ក៏ដូចជាការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង គឺក្រោយពីបញ្ចប់ការចុះឈ្មោះបោះឆ្នោត ៤ថ្ងៃក្នុងករណីគ្មានបណ្ដឹងតវ៉ា ស្មៀនឃុំនឹងបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៅគ្រប់ឃុំ-សង្កាត់ទាំងអស់ ។ ក្នុងដំណាក់កាលទាំងពីរគឺ ការពិនិត្យបញ្ជីឈ្មោះ និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង សង្កេតឃើញថា ពលរដ្ឋពុំបានយកចិត្តទុកដាក់លើរឿងនេះទេ ដែលនេះគឺជាចំណុចខ្វះខាត ។

ចំពោះពលរដ្ឋទើបគ្រប់អាយុ ១៨ឆ្នាំ សំរាប់ឆ្នាំមិនបោះឆ្នោត គិតត្រឹមថ្ងៃ ៣១ ធ្នូ រៀងរាល់ឆ្នាំ តែសំរាប់ឆ្នាំបោះឆ្នោត ត្រូវគិតដល់ថ្ងៃបោះឆ្នោត ជាក់ស្ដែងនៅឆ្នាំ២០០៧ ខាងមុខនេះ នឹងបោះឆ្នោតនៅថ្ងៃ ១ មេសា ២០០៧ ដូច្នេះត្រូវគិតដល់ថ្ងៃបោះឆ្នោត ។ ឯអ្នកផ្លាស់ចូលនៅក្នុងឃុំ-សង្កាត់ ត្រូវអញ្ជើញមកចុះឈ្មោះថ្មី ។ កន្លងមក យើងជួបបញ្ហានានា ដូចជា អ្នកមកចុះឈ្មោះថ្មីដោយគ្មានឯកសារបញ្ជាក់ តែអ្នកខ្លះមានដែរ តែមានបញ្ហាសញ្ជាតិ ជូនកាលរកឯកសារបាន ផុតពេលបោះឆ្នោត ។ ក្រោយពេល គជប ធ្វើប្រតិភូកម្មអំណាចឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ស្មៀនឃុំ ក៏នៅមិនច្បាស់ពីរឿងនេះដែរ ។ លុះដល់ឆ្នាំ២០០៥ នេះ យើងសង្កេតឃើញថា ទាំងប្រជាពលរដ្ឋ និងស្មៀន ក៏ដូចជា តំណាងគណបក្សនយោបាយដែលបានចូលរួមសង្កេតការណ៍ មានការយល់ដឹងលើដំណើរការនេះច្រើន ដែលឃើញការប្រែប្រួលនៃកំរិតយល់ដឹងលើការងារចុះឈ្មោះបោះឆ្នោត ។ ចំណែកឯអ្នកស្លាប់ ផ្លាស់ចេញ អ្នកគ្មានទីលំនៅប្រាកដ និងអ្នកត្រូវដកសិទ្ធិបោះឆ្នោត ឃុំនឹងត្រៀមឯកសារនេះ ដើម្បីលុបឈ្មោះអ្នកទាំងនោះចេញពីបញ្ជីបោះឆ្នោត សំដៅធ្វើបញ្ជីបោះឆ្នោតនៅតាមការិយាល័យនីមួយៗ កាន់តែមានភាពសុក្រឹត ។

ជាលទ្ធផលនៅឆ្នាំ២០០៥ យើងចុះឈ្មោះថ្មីបាន ៨.៣៦៥នាក់ ស្មើនឹង ៥៨,២៥% នៃចំនួនប៉ាន់ស្មានអ្នកត្រូវចុះឈ្មោះអ្នកបោះឆ្នោត ១៤.៣៥១នាក់ និងបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតឆ្នាំ២០០៤ ចំនួន ១.៩៦៨នាក់ អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទូទាំងខេត្តមាន ២៣៥.៦៩៤នាក់ ស្មើនឹង ៩៦,៧៣% នៃចំនួនប៉ាន់ស្មានពលរដ្ឋអាយុ ១៨ឆ្នាំឡើង ២៤៣.៦៤៨នាក់ និងមានការិយាល័យបោះឆ្នោតចំនួន ៥០៩ការិយាល័យ ។ តាមការស្រង់ស្ថិតិប៉ាន់ស្មានពីគ្រប់ឃុំ ខេត្តនេះនឹងមានពលរដ្ឋអាយុ ១៨ឆ្នាំឡើងគិតដល់ថ្ងៃ ១ មេសា ២០០៧ នឹងត្រូវចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៦ ប្រហែល ១៦.៥៣៥នាក់ ។ នេះជាលទ្ធផលមួយ ក្នុងចំណោមលទ្ធផលនានាដែលក្រុមប្រឹក្សាឃុំ ស្មៀន ខិតខំយកចិត្តទុកដាក់សំរេចបានក្នុងពេលតែមួយនៅមូលដ្ឋានរបស់ខ្លួន ។ ទន្ទឹមនេះ គជប បានដាក់ចេញនូវនីតិវិធីថ្មីមួយទៀត នាខែកក្កដា ២០០៥ គឺការត្រៀមចុះឈ្មោះបោះឆ្នោត ដើម្បីជួយសំរួលប្រជាពលរដ្ឋដែលមិនទាន់បានចុះឈ្មោះ មានអាយុគ្រប់ ១៨ឆ្នាំ មានពេលវេលា រកឯកសារមកបំពេញលក្ខខណ្ឌចុះឈ្មោះ ។ ដោយត្រូវចុះឈ្មោះពីរដង ដំបូងត្រូវមកជួបស្មៀន ចុះឈ្មោះត្រៀម និងបានទទួលពត៌មានពីស្មៀនវិញ ថាគាត់មានគ្រប់ ឬខ្វះឯកសារណាមួយ ដើម្បីមានពេលរកឯកសារនោះមកបង្គ្រប់ ដែលបានធ្វើនៅឆ្នាំ២០០៥ តាំងពីថ្ងៃ ១ មករា ដល់ ៣០ កញ្ញា ។ លើកទី ២ ត្រូវមកជួបស្មៀន ដើម្បីចុះឈ្មោះម្ដងទៀត ដែលជាការចុះឈ្មោះផ្លូវការ ដែលច្បាប់តំរូវឱ្យអ្នកចុះឈ្មោះមកបង្ហាញខ្លួន និងមានឯកសារគ្រប់លក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោត ។ ដូច្នេះដំណើរការនៃការចុះឈ្មោះបោះឆ្នោតជាផ្លូវការសំរាប់ឆ្នាំ២០០៦ នឹងប្រព្រឹត្តទៅនៅថ្ងៃ ១ -២០ តុលា ២០០៦ ។ គជប បានរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត ទៅតាមអក្ខរក្រមខ្មែរ ដើម្បីឱ្យពលរដ្ឋងាយស្រួលរកឈ្មោះ ហើយថ្មីៗនេះ គជប បានដាក់ចេញនីតិវិធីថ្មីមួយទៀត ហើយនៅគ្រប់ខេត្ត-ក្រុងទាំងអស់កំពុងដំណើរការ គឺការផ្ដល់ប័ណ្ណពត៌មានអ្នកបោះឆ្នោត មុនការពិនិត្យបញ្ជីចុះឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៦ ដើម្បីឱ្យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានដឹងអំពីលេខរៀង ឈ្មោះនិងទិន្នន័យ លេខកូដនិងទីតាំងការិយាល័យបោះឆ្នោត ដឹងពីកាលបរិច្ឆេទនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដឹងពីបណ្ណអត្តសញ្ញាណផ្លូវការដែលត្រូវកាន់ទៅបោះឆ្នោត និងឈប់ប្រើប័ណ្ណបោះឆ្នោតឆ្នាំ១៩៩៣ ១៩៩៨ និង២០០២ ។ ការផ្ដល់ប័ណ្ណពត៌មានគឺធ្វើឡើងដោយក្រុមប្រឹក្សាឃុំផ្ទាល់ សហការជាមួយមេភូមិ នៅតាមភូមិនៃឃុំនីមួយៗ ។

ឆ្លងតាមការផ្ដល់ប័ណ្ណពត៌មាន ក្រុមប្រឹក្សាឃុំ និងមេភូមិ អាចកត់សំគាល់បានអ្នកបោះឆ្នោតមានឈ្មោះខុស អក្ខរាវិរុទ្ធ ដែលមិនដូចនឹងអត្តសញ្ញាណប័ណ្ណ ដែលត្រូវកាន់ទៅបោះឆ្នោត ក្ដាប់បានចំនួនពលរដ្ឋដែលអះអាងថាធ្លាប់បានបោះឆ្នោត តែអត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ ក្រុមប្រឹក្សាឃុំ និងមេភូមិ ក៏អាចក្ដាប់បានចំនួនពលរដ្ឋដែលមានអាយុគ្រប់ ១៨ឆ្នាំ អ្នកផ្លាស់ចូល ត្រៀមអញ្ជើញឱ្យទៅចុះឈ្មោះផ្លូវការនៅថ្ងៃ ១-

២០ តុលា ខាងមុខ ។ ក្រុមប្រឹក្សាឃុំ និងស្មៀន អាចសំគាល់ពីប័ណ្ណដែលមិនបានចែកជូនពលរដ្ឋ ដោយអ្នកនោះបានស្លាប់ បានផ្លាស់ចេញ គ្មានទីលំនៅក្នុងភូមិ ឃុំ អ្នកបោះឆ្នោតមានឈ្មោះស្ទួន ដើម្បីឱ្យមានពេលគ្រប់គ្រាន់ ត្រៀមឯកសារបំពេញបែបបទ ទុកនៅពេលបោះឆ្នោតផ្លូវការ ។

ក្រុមប្រឹក្សាឃុំ និងមេភូមិ កត់សំគាល់បានអ្នកបោះឆ្នោតដែលគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ ដើម្បីឱ្យត្រៀមរូបថត បំពេញទំរង់ ១០១៨ សំរាប់កាន់ទៅបោះឆ្នោត ។ នេះជាចំណុចពិសេស ចំពោះពលរដ្ឋដែលមានឈ្មោះបោះឆ្នោត ករណីគ្មានអត្តសញ្ញាណប័ណ្ណ គជប សំរួលដោយចេញទំរង់ ១០១៨ ជូនពលរដ្ឋទាំងនោះ បានទៅបោះឆ្នោត ។ ការផ្តល់ប័ណ្ណពត៌មានចាប់ដំណើរការតាំងពីថ្ងៃទី ០១ -៣១ សីហា ២០០៦ ។ នៅខេត្តកំពង់ឆ្នាំង គិតត្រឹមថ្ងៃ ១៥ សីហា ២០០៦ បានផ្តល់ប័ណ្ណជូនសាមីខ្លួនចំនួន ២៨.៦០៤ប័ណ្ណ ផ្តល់តាមរយៈតំណាងបានចំនួន ២៩.៧៧៩ប័ណ្ណ សរុបទូទាំងខេត្តបានផ្តល់ចំនួន ៥៨.៣៨៣ប័ណ្ណ ស្មើនឹង ២៤,៧៧% នៃចំនួនប័ណ្ណពត៌មានសរុប ២៣៥.៦៩៤ប័ណ្ណ ។

ឆ្លងតាមការផ្តល់ប័ណ្ណពត៌មាននេះ យើងបានរកឃើញអ្នកបោះឆ្នោតដែលបានស្លាប់ ៣១៨នាក់ ផ្លាស់ទីលំនៅចេញ ៥០៦នាក់ អ្នកគ្មានលំនៅអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នចំនួន ១២២នាក់ អ្នកបោះឆ្នោតមានឈ្មោះស្ទួន ៣៨នាក់ ។ តួលេខនេះ មិនទាន់ប្រមូលបានគ្រប់ឃុំនៅឡើយទេ ។ មុនពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ថ្ងៃ ០១ មេសា ២០០៧ នឹងផ្តល់ប័ណ្ណពត៌មាននេះម្តងទៀត ក្នុងបំណងផ្តល់ឱ្យអ្នកបោះឆ្នោតដឹងពីកាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ដឹងពីលេខរៀង ទិន្នន័យឈ្មោះ លេខកូដនិងទីតាំងការិយាល័យបោះឆ្នោត និងឱ្យអ្នកបោះឆ្នោតត្រៀមឯកសារបញ្ជាក់អត្តសញ្ញាណណាមួយផ្លូវការសំរាប់កាន់ទៅបោះឆ្នោត ។ ការផ្តល់ម្តងនេះ នឹងមិនមានការកែប្រែអ្វីឡើយ ។ បើគ្មានទេ ត្រូវបំពេញទំរង់ ១០១៨ ដោយមានបិទរូបថត ។ ចំណុចដែល គជប យកចិត្តទុកដាក់គឺ នៅតាមការិយាល័យបោះឆ្នោតនឹងមានបន្ថែមជំនួយការម្នាក់សំរាប់ជួយរកមើលឈ្មោះអ្នកបោះឆ្នោត ដែលឈរនៅខាងក្រៅ បង្ការមិនឱ្យមានបញ្ហាអ្វីកើតឡើង ។ អ្វីដែលបានរៀបរាប់ ជានីតិវិធីល្អ ដើម្បីកាត់បន្ថយបញ្ហានានាដែលអាចកើតមានឡើងក្នុងដំណើរការបោះឆ្នោត និងនៅពេលបោះឆ្នោត ។ ទាំងអស់នេះអាចកាត់បន្ថយបាន គឺអាស្រ័យដោយមានការចូលរួមពីគ្រប់ស្ថាប័ន ភាគីពាក់ព័ន្ធនានា ដែលទាមទារឱ្យភាគីទាំងនោះគោរពបាននូវនីតិវិធី បទបញ្ជា ច្បាប់បោះឆ្នោតរបស់ គជប ពិសេសត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់ខ្លួន ។ ក្នុងនាមជាលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកំពង់ឆ្នាំង សូមគាំទ្រនិងសង្ឃឹមថា ឧប់សែលប្រ៉ម នឹងបំផុសគំនិត និងអនុសាសន៍ល្អៗ ដើម្បីបំពេញលើចំណុចខ្វះខាតកន្លងមក សំដៅឱ្យការបោះឆ្នោតទាំងពីរខាងមុខ ទទួលបានលទ្ធផលកាន់តែប្រសើរឡើងថែមទៀត ។

**លោក ឱក សេរី សោភ័ក្តិ** អរគុណលោកស្រី នួន ចន្ទី ដែលមានប្រសាសន៍ជុំវិញការងារបោះឆ្នោតនៅខេត្តកំពង់ឆ្នាំង ដោយបញ្ជាក់ពីអ្វីដែល គជប បានដាក់ចេញ ហើយ គជបខ បានអនុវត្ត ដើម្បីសំរួលជូនអ្នកបោះឆ្នោត ។ យើងបានស្តាប់នូវរបាយការណ៍បែបនេះច្រើន ដូច្នេះធ្វើឱ្យបានដឹងថារបាយការណ៍ណាដែលស្មោះ ត្រង់ ដោយមិនបញ្ចេញបញ្ចូល ។ យើងមានមោទនភាពណាស់ ក្នុងនាមយើងជាខ្មែរ ដោយក្នុងខេត្តទាំង ៥ ប្រធានលេខាធិការដ្ឋានរៀបចំការ បោះឆ្នោតក្នុងខេត្ត បី ជានារី គឺនៅបន្ទាយមានជ័យ ក្រុងប៉ៃលិន និងកំពង់ឆ្នាំងនេះ ។ គជប បានផ្តល់អាទិភាពដល់ស្ត្រីច្រើនណាស់ ក្នុងការរៀបចំការ បោះឆ្នោត ហេតុនេះបានជា ឧប់សែល ផ្តល់ឱកាសដល់ស្ត្រីស្មើនឹងបុរស ដូចដែលរដ្ឋធម្មនុញ្ញបានចែង ។ បើសិនប្រទេសមួយដែលមាន ៥២% ជាស្ត្រី បានដើរតួនាទីច្បាស់លាស់ជាពិសេសក្នុងការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ ប្រទេសនោះមិនអាចដើរថយក្រោយបានទេ មានតែជឿនលឿនថែម ទៀត ។ ជាបន្តលោកប្រគល់ប្រសាសន៍ជូនអ្នកចូលរួមទាំងអស់ តែសុំកុំចាំបាច់អរគុណច្រើនពេក ដើម្បីកុំឱ្យខាតពេល ដោយបង្ហាញឈ្មោះ មកពី ស្ថាប័នណា ដែលមានពេលតែ ៥នាទី ដោយសារយើងមានគ្នាច្រើន ។ បន្ទាប់ពីលោក លោកស្រី បានមានប្រសាសន៍ ៥-៧នាក់ នឹងអនុញ្ញាតឱ្យ លោកស្រីប្រធានលោខាធិការដ្ឋានធ្វើការបញ្ជាក់ បើសិនជាមាន ។ លោកស្រីមិនចាំបាច់បញ្ជាក់ទេចំពោះអនុសាសន៍ដែលអង្គប្រជុំបានលើកសំណើឡើង ទៅលើចំណាប់អារម្មណ៍ ដោយគ្រាន់តែឆ្លើយសំណួរដែលគេសួរ ដោយសុំខ្លីៗ ។ លោកបានបញ្ជាក់បន្ថែមថា បើសិនជាមានសង្គមស៊ីវិល ឬគណបក្ស ឬខាងប្រធានមន្ទីរ មើលឃើញថាជាចំណុចអវិជ្ជមាន ហើយចង់លើកឡើង សុំឱ្យច្បាស់ថាតើភូមិសាស្ត្រនៅកន្លែងណា ភូមិឈ្មោះអ្វី អ្នកណាធ្វើខុស ខ្វះចន្លោះកន្លែងណា ដោយសារអ្នកដែលធ្វើការល្អមានច្រើន ដូចនេះបើមានអ្នកធ្វើមិនល្អមានតែមួយ ហើយនិយាយមិនចំ ធ្វើឱ្យយើង

ទាំងអស់គ្នា មានអារម្មណ៍សុទ្ធតែធ្វើការមិនល្អ ហើយពិបាកស្រាវជ្រាវ ។ យន្តការខប់សែល មានគោលបំណងទៅដល់កន្លែងណាដែលអវិជ្ជមាន នឹងចុះទៅទីនោះ ដោយសហការជាមួយស្ថាប័ននានា ដើម្បីកែតំរូវ ។ សូមបញ្ជាក់ថា កំណត់ហេតុមានតំលាភាព ១០០% លោក លោកស្រីមានប្រសាសន៍យ៉ាងណា កំណត់ហេតុនឹងរាយការណ៍បែបនោះ ដោយសារយើងបានអាត់សម្លេងទុក ។ អ្នកណាមានប្រសាសន៍ អ្នកនោះទទួលខុសត្រូវ ។ កំណត់ហេតុនឹងផ្ញើថ្វាយព្រះមហាក្សត្រ រាល់ខែ ព្រះអង្គតែឆ្លើយមកវិញរាល់ខែដែរ គួរឱ្យគោរពណាស់ ផ្ញើជូនសម្តេចប្រធានព្រឹទ្ធសភា រដ្ឋសភា សម្តេចនាយរដ្ឋមន្ត្រី ឧបនាយរដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាល គណបក្សទាំងអស់ សង្គមស៊ីវិល អង្គការអន្តរជាតិ ថ្នាក់មូលដ្ឋានខេត្ត បានទទួលទាំងអស់ ។ បំណងមកធ្វើនៅខេត្តនេះ គឺចែកចាយទៅខេត្តឯទៀត១ប្តូរដំណឹងគ្នាទៅវិញទៅមក ឱ្យដឹងថា ខប់សែល នៅទីនេះ លើកឡើងរឿងអ្វី ខេត្តនេះមានបញ្ហាអ្វី ។ ដូច្នេះកំណត់ហេតុនេះ ជាសារបញ្ជូនដំណឹងគ្នាទៅវិញទៅមក ។

លោក **កែវ ឆយ** ជំទប់ទី ២ ឃុំច្រេស ហ៊ុនសិនបិុច លោកមានចម្ងល់ពីការធ្វើអត្តសញ្ញាណប័ណ្ណ និងប័ណ្ណគ្រួសារ ច្បាប់កំណត់ថា មិនឱ្យយកលុយពីពលរដ្ឋទេ តែដល់ពេលពលរដ្ឋទៅធ្វើ យក ២០.០០០៛ និងប័ណ្ណបន្ទុកយក ៥.០០០៛ អត្តសញ្ញាណប័ណ្ណយក ២.០០០៛ ដូច្នេះពលរដ្ឋនៅជនបទក្រីក្រ មិនដូចនៅទីក្រុងទេ មិនអាចធ្វើប័ណ្ណទាំងនោះបានទេ មិនបានទៅចុះឈ្មោះបោះឆ្នោតទេ ។ អង្គការ Plan ធ្វើសំបុត្រកំណើតឱ្យ ដោយមិនយកប្រាក់ ផ្ទុយទៅវិញប្រធានភូមិខ្លះ យក ១០០៛/ស្រោមសំបុត្រ ដូច្នេះនៅពេលហៅពលរដ្ឋទៅប្រជុំដើម្បីផ្តល់ប័ណ្ណពតិមាន គ្មានពលរដ្ឋណាទៅចូលរួមទេ ដោយខ្លាចទារលុយទៀត ។ នេះជាបញ្ហាមួយ ។ មួយវិញទៀតបញ្ហាពលរដ្ឋដែលគ្មានអត្តសញ្ញាណប័ណ្ណ និងសៀវភៅគ្រួសារ តែមានប័ណ្ណបោះឆ្នោត មិនបានចុះឈ្មោះ សូមលោកស្រីជំរាប ដល់ស្មៀនផង ។ ឯ ស្មៀន គ្រាន់តែសំបុត្រកំណើតមួយ យក ៣.០០០៛ ពីមុនយកតែ ៥០០៛ រហូតដល់ប្រកាសជាសុពលភាពទៀត ។ ដូច្នេះ តើមានសំបុត្រកំណើតអាចទៅចុះឈ្មោះបោះឆ្នោតបានទេ? អាចទៅធ្វើ ១០១៨ បានទេ? ហើយបើគ្មានឯកសារអ្វីសោះ សុំឱ្យស្មៀនបន្ថយលុយ បន្តិចមក ដើម្បីឱ្យអ្នកទៅចុះឈ្មោះ មានសេចក្តីសេចក្តីក្លាហាន ។២០០០៛ នៅស្រុកស្រែច្រើនណាស់ ។

លោក **ង៉ែត សារឿម** សមាជិកក្រុមប្រឹក្សាឃុំពពេល សុំរាយការណ៍ពីការចុះអនុវត្តផ្ទាល់លើការចែកប័ណ្ណពតិមានជូនពលរដ្ឋ ។ ក្នុងមូលដ្ឋានលោក គួរឱ្យសោកស្តាយដែលសមាជិកភូមិ មេភូមិ អនុប្រធានភូមិ ដែលមកពីគណបក្សតែមួយ តែគណបក្សឯទៀតអត់មានទេ ។ លោកស្ទាបស្ទង់អំពីការមិនស្មើភាពរបស់ពួកគាត់ដែរ ។ ចំណុចទី ២ លោកសូមចាប់អារម្មណ៍លើការធ្វើ អត្តសញ្ញាណប័ណ្ណ ។ សមត្ថកិច្ចប៉ូលីសបានចុះធ្វើជូនពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើង ដែលពតឹមាននោះ ប្រហាក់ប្រហែលនឹងលោកខាងដើមដែលបានជំរាបរួច ដោយសុំពិនិត្យតារាង ក១, ក៤ (សៀវភៅគ្រួសារ) និងអត្រានុកូលដ្ឋាន ការផ្ទៀងផ្ទាត់ ឯកសារទាំង៣ ជួនកាលប្រក្រតី ដោយត្រូវតាមអក្ខរាវិរុទ្ធ តែពេលផ្ទៀងមិនត្រូវ ដូចជា ខ្វះ ក១ ប៉ូលីសទារ ៥.០០០៛ សៀវភៅគ្រួសារទារ ១៥.០០០៛-២០.០០០៛ អត្រានុកូលដ្ឋានដែលត្រូវទៅរៀននៅអនុវិទ្យាល័យខុសគ្នា ។ នេះជាចំនុចអវិជ្ជមានមិនអាចទទួលលទ្ធផលបានទេ ។ ដូច្នេះ ការផ្តល់អត្តសញ្ញាណប័ណ្ណបានតិចតួចបំផុត ។ នេះសុំឱ្យអស់លោកជួយកែតំរូវឱ្យ ដោយផ្តល់អាទិភាពឱ្យបាន ចុះឈ្មោះបានដោយងាយស្រួល ។ បើអនុវត្តតាមទំរង់ ១០១៨ ពលរដ្ឋនៅតែអស់លុយ ដោយត្រូវថតរូប ៣.០០០៛ ។ ដូចនេះសូមបង្កលក្ខណៈងាយ ស្រួលដល់ពលរដ្ឋលើបញ្ហានេះ ។

លោក**ស្រី គី សុភាព** តំណាងគណបក្ស សម រង្ស៊ី នៅពេលនេះជាដំណាក់កាលនៃការចែកប័ណ្ណពតិមាន ។ លោកស្រីសង្កេតឃើញមានភាពមិនប្រក្រតី និងមានការយឺតយ៉ាវយ៉ាងណា ដូចជា ឃុំកំពង់ ត្រឡាចក្រោម ដែលចាប់អនុវត្តការចែកប័ណ្ណនេះ ពីថ្ងៃទី ១៤-១៨ តាមប្រតិទិន តែថ្ងៃ ១៤ លោក កែវ សាន សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុក ចែកប័ណ្ណនេះ មិនបានទៅចែកទេ ថ្ងៃ ១៥ ទៅប្រជុំគណបក្សស្រុក ដល់ថ្ងៃ១៦ ទើបបានចែកប័ណ្ណនេះ តែមួយថ្ងៃគត់ ហើយនៅពេលចែកនោះមិនឃើញវត្តមានគាត់ទេ លោកស្រីបាន សួរទៅពលរដ្ឋជាសកម្មជនដែលនៅទល់មុខកន្លែង

ចែកថា តើបានទទួលប័ណ្ណពតិមានឬនៅ? គេឆ្លើយថា មិនទាន់ទទួលទេ ។ លោកស្រីយល់ថា ទីតាំងចែកចំកណ្តាលឃុំ គឺល្អណាស់ តែហេតុអ្វីប្រជាជននៅទល់មុខកន្លែងនោះមិនបានទទួល ដោយសារគេចែកចោះៗ មិនបានទូលំទូលាយទេ ។ ដោយហេតុថា នេះជាវេទិកាដែលអ្នកនិយាយដោយត្រង់ទៅត្រង់មកនិយាយអ្វីក៏បានដែរ ដោយលើកបញ្ហានិយាយនៅចំមុខគ្នា ដូច្នេះខ្ញុំសូមនិយាយឱ្យត្រង់ ឱ្យអស់សេចក្តី។ រាល់ថ្ងៃការចែកប័ណ្ណពតិមាន គជប ផ្តល់ អាទិភាពទៅឱ្យក្រុមប្រឹក្សាឃុំ មេឃុំ/សមាជិកក្រុមប្រឹក្សាណាម្នាក់ ជាអ្នកចែកចាយប័ណ្ណពតិមានដល់ពលរដ្ឋ ។ ឆ្លៀតឱកាសនេះ លោកស្រី បានលើកយកបញ្ហាមួយចំនួន ដោយផ្តល់ជាឧទាហរណ៍ អាជ្ញាធរដែនដី មានគណបក្សតែមួយគឺ គណបក្សប្រជាជន ឯអ្នកចែកប័ណ្ណពតិមាន គឺមានឱកាស តែគណបក្សប្រជាជន ហេតុអ្វីបានជាសកម្មជននៅ ចំពីមុខកន្លែងចែកហើយមិនបានទទួលប័ណ្ណនោះ ដែលអ្នកខ្លះទៀតបានទទួល បើសិនការចែកប័ណ្ណនេះ តែមួយកន្លែងដូច្នេះ ពលរដ្ឋនឹងនៅតែមិនបានទទួលគ្រប់គ្នា ជាក់ស្តែងនៅក្នុងឃុំច្រកល្មៀត អ្នកដែលមិនទាន់ទទួលប័ណ្ណពតិមាន ដែលប័ណ្ណនេះនៅសល់រហូតដល់ ២៧០ប័ណ្ណ ដោយសារពេលនេះ ជាពេលធ្វើស្រែ ជាសំណូមពរ បើសិនជាអាចធ្វើបាន សុំឱ្យដើរចែកតាមផ្ទះ តែសុំកុំចែករំលង សកម្មជនគណបក្ស សម រង្ស៊ី សុំចែកឱ្យស្មើភាព ។ ឯការយឺតយ៉ាវក្នុងការចែកប័ណ្ណពតិមាននេះ បើសិនជាគេមានបំណងមិនចែកឱ្យគ្រប់ៗគ្នា ជាពិសេសចំពោះគណបក្សណាមួយដែលគេយល់ថា នឹង មិនចំណេញ មិនបាច់ចែកឱ្យ ដោយបង្ហាក់ឱ្យនៅសល់ប័ណ្ណ ហើយគេនឹងលបចែកស្ងាត់ៗ បានចំពោះអ្នកណាស្គាល់កំលាំងណាគាំទ្រខាងខ្លួនពិតប្រាកដ នៅពេលគេស្គាល់កំលាំងមិនគាំទ្រ នឹងនៅតែអត់ឱកាស ដល់ពេលបោះឆ្នោតអត់មាន ប័ណ្ណពតិមាន បើទោះជាមានក៏ដោយ ក៏ខុស ៨០% ដែរ ។ បើមិនខុសឈ្មោះ ខុសឆ្នាំកំណើត សូម្បីតែប្រធានគណបក្សស្រុករបស់លោកស្រីក៏ខុសដែរ ឧទាហរណ៍ ក្នុងភូមិស្តិពន្លិច ក្រុមប្រឹក្សាគណបក្សនៅភូមិ របស់លោកស្រី ប្រពន្ធគាត់ ក៏ខុសអាយុដែរ សមាជិកលោកស្រីពីរនាក់បងប្អូនខុសអាយុ ទាំងពីរ ដូច្នេះ ការធ្វើប័ណ្ណពតិមាននេះ វាខុសច្រើនណាស់ បើនៅតែបន្តចែករបៀបនេះ នឹងមិនទៅដល់ដៃប្រជាពលរដ្ឋទេ គ្មានឱកាសមកផ្ទៀងផ្ទាត់ ទេ ដោយសារច្បាប់ថា បើមានខុសត្រង់ណា នឹងមិនអាច បោះឆ្នោតបានទេ ។ សុំឱ្យចែកប័ណ្ណពតិមាននេះជាបណ្តើរៗចាប់ពីពេលនេះទៅ បើមិនដូច្នេះ ទេ ដល់ថ្ងៃទី ០១-២០ តុលា  ស្មៀនឃុំម្នាក់ឯងទទួល ភារកិច្ចច្រើនណាស់ ទោះជារួមធ្វើការជាមួយក្រុមប្រឹក្សាឃុំក៏ដោយ ចុះឈ្មោះអ្នកថ្មីផង កែ ប័ណ្ណពតិមានផង ពេលវេលា ២០ថ្ងៃ មិនគ្រប់ទេ ។ ដោយសារនេះជាការចែកលើកទី ១ ហើយចែកលើកក្រោយនឹងយកជាផ្លូវការ បើខុសត្រូវត្រៀម ១០១៨ សុំ គជប ជួយសំរួលថតរូបជូនពលរដ្ឋផង ព្រោះពលរដ្ឋគ្មានលុយថតរូបទេ បើធ្វើបែបនេះ អ្នកអត់បោះឆ្នោតគឺមានកាន់តែច្រើន ។

**លោក ឱក សេរី សោភក្តិ** អរគុណវាគ្មិនទាំងអស់ដែលបានលើកឡើង ហើយសុំជំរាបថា ពតិមានដែលយើងបានទទួលនេះ គឺនៅខេត្ត ៤ទៀត ក៏ ប្រហែលគ្នាដែរ ។ នេះជា ការសំខាន់ណាស់ កន្លែងណាដែលខ្វះខាត ដូចដែលបងស្រីមានប្រសាសន៍ សុំប្រាប់ឈ្មោះឃុំ ធ្វើមិនល្អយ៉ាងម៉េចខ្លះ អ្នកណាទទួលខុសត្រូវ សុំចង្អុល បែបនេះមក ដើម្បីធ្វើការកែប្រែ ហើយមានការទិតៀនលើ គជប ច្រើនណាស់ ក្នុងរឿងចែកប័ណ្ណពតិមាន ។ បើ គជប មានបំណងមិនបរិសុទ្ធ នឹងមិនបង្កើតប័ណ្ណពតិមាននេះទេ នៅពេលបង្កើតប័ណ្ណពតិមាននេះ ធ្វើឱ្យយន្តកានេះ បើកទូលាយ ដោយដឹងថាអ្នកណាធ្វើការខ្វះខាត បញ្ហានៅមាន ត្រង់ណា ហើយមានគំរោងយកបញ្ហាដែលបងស្រីមានប្រសាសន៍ ដើម្បីកែតំរូវលើបញ្ជីឈ្មោះ ទាន់យើងនៅមានពេល ។ នៅឆ្នាំ២០០៥ បញ្ហាដែល ស្មៀនឃុំចុះមិនបានច្រើន ដោយសារតែ ២០ថ្ងៃនេះ ខាងសីលា ក្រសួងមហាផ្ទៃ សង្គមស៊ីវិល អញ្ជើញស្មៀនទៅបំពាក់បំប៉ន ដូច្នេះរយៈពេលចុះឈ្មោះ តែមួយអាទិត្យគត់ មិនមែន ២០ថ្ងៃទេ ។ នៅឆ្នាំនេះ យើងធ្វើការជាមួយខាង គជប សីលា ក្រសួងមហាផ្ទៃ សុំឱ្យធ្វើប្រាកដ ២០ថ្ងៃ សុំបញ្ជៀស កម្មវិធីនានាដែលចំរយៈពេល ២០ថ្ងៃ (០១-២០ តុលា) ហើយផ្តួបគ្នាជាមួយ នឹងយុទ្ធនាការចុះឈ្មោះត្រៀមពីខែមករា ដល់កញ្ញា ជាមួយនឹង ប័ណ្ណពតិមាន ដែលយើងបានឃើញបញ្ហាអស់ហើយ ផ្សំនឹងការធ្វើការជាបណ្តើរៗ សង្ឃឹមថា នឹងអាចកែប្រែស្ថានការណ៍បាន ។ ទីបញ្ចប់នៅខែមីនា នឹងធ្វើការចែកប័ណ្ណនេះម្តងទៀត ដើម្បីពិនិត្យជាចុងក្រោយទាំងអស់គ្នា ។ ដូច្នេះយើងឃើញថា យន្តការនៃការបោះឆ្នោត កាន់តែមានភាពសុក្រឹត ។ នៅពេលធ្វើការបើកចំហបែបនេះ ទើបមើលឃើញកន្លែងខ្វះខាត ហើយយើងមានពេលកែតំរូវ ។

លោក **ឡុង ធី** ជំទប់ទី ២ នៅឃុំគ្រាំងស្គា គណបក្សសម រង្ស៊ី សូមបញ្ជាក់អំពីឈ្មោះក្នុងបញ្ជីបោះឆ្នោត ក្នុងអត្តសញ្ញាណប័ណ្ណ និងសៀវភៅគ្រួសារ ។ ឈ្មោះដែលមានក្នុងបញ្ជីទាំងបី មិនត្រូវគ្នាទាំងអស់ ទាំងអក្ខរាវិរុទ្ធ និងទិន្នន័យផ្សេងទៀត លោកបានសង្កេតឃើញជាក់ស្តែង នៅក្នុងឃុំរបស់លោក ផ្ទាល់ ឧទាហរណ៍ ក្នុងអត្តសញ្ញាណប័ណ្ណឈ្មោះ សឿង ឯនៅក្នុងបញ្ជីបោះឆ្នោតសរសេរថា សន ទៅវិញ ។ នេះជាបញ្ហាដែលបណ្តាលឱ្យយឺតយ៉ាវ និងពិបាកធ្វើការ ។ ដូច្នេះលោកម្នាក់នោះ នឹងមិនបានបោះ ឆ្នោត ។ ឥឡូវនេះ ជាពេលត្រូវចែកប័ណ្ណពតិមានបោះឆ្នោត ចំពេលដែលពលរដ្ឋ រវល់ដកស្ទូង នៅពេលមន្ត្រីទៅចែក គឺធ្វើមួយថ្ងៃក្នុងមួយភូមិ ។ ដូច្នេះយើងឃើញថា ពិតជាធ្វើការចែកមិនអស់ប័ណ្ណទេ និងមិនជូនដំណឹងឱ្យភូមិ បានដឹងជាមុនទេ ឧទាហរណ៍ នៅភូមិតាសាំ អត់មានប្រជាជន ដោយសារមន្ត្រីទទួលខុសត្រូវ (ម៉ែន សឹន) នោះ មិនបានជូនដំណឹងជាមុនដល់មេភូមិ ដើម្បីឱ្យប្រមូលគ្នាចាំទទួលប័ណ្ណពតិមាន ។

**លោក ឱក សេរី សោភក្តិ** ដូច្នេះបញ្ហាប្រឈមដែលបានលើកឡើងមានបី ។ ទី១ បញ្ហាខុសឈ្មោះពីឯកសារមួយទៅមួយ ទី២ ការមិនបានផ្តល់ដំណឹង អំពីការចែកប័ណ្ណពតិមានបោះឆ្នោតឱ្យបានគ្រប់ជ្រុងជ្រោយ ទី៣ ហាក់ដូចជាមានអារម្មណ៍ថា ការចែកនេះមានការរើសអើង ដោយសារចែកចោះៗ ។

លោក **អ៊ុក គីឡា** ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានប្រចាំខេត្តកំពង់ឆ្នាំង នេះជាលើកទី ១ ហើយដែលលោកបានចូលរួមក្នុងកិច្ចប្រជុំមួយដ៏មានអត្ថន័យសំខាន់ជុំវិញការងារបោះឆ្នោត ដែលហៅថា យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជាខេត្ត-ក្រុង ហៅកាត់ថា ខប់សែលប្រ៊ម ដែលមានលោក សោភក្តិ ជាអ្នកសំរបសំរួល ។ ការងារបោះឆ្នោតនេះជាការមមាញឹក របស់ក្រុមប្រឹក្សាឃុំ មេភូមិ ស្មៀន ។ អ្វីដែលលោកលើកឡើងនេះ គឺក្នុងបរិកាសអព្យាក្រឹត ។ ជុំវិញការចែកប័ណ្ណពតិមានដែលបានចែកជូន ដូចលោកស្រី នួន ចន្ទី បានលើកឡើង គឺមិនទាន់បាន ៥០% ទេ គឺ ២៤,៧៧% លោកជឿជាក់ថា ការចែកនេះគឺមិនប្រកាន់ថា គណបក្សប្រជាជន ហ៊្វុនស៊ិនប៊ិច ឬ សម រង្ស៊ី ទេ នេះគឺជារូបភាពសត្យានុម័ត ។ តាមការសាកសួរ អ្នកដែលនៅជុំវិញតុនេះ ខ្លះមិនទាន់បានទទួលប័ណ្ណនេះដែរ ។ ដូច្នេះការចែកនេះមានចែកចេញជាដំណាក់កាល ។ ការចែកជូននៅឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង គឺមិនប្រកាន់បក្សពួកអ្វីទេ មិនតំរូវទៅលើគណបក្ស ណាមួយទេ ។ បើនិយាយពីភារកិច្ចរបស់ស្មៀន ដែលការប្រជុំនៅសាលសន្និសីទចតុមុខ ម្សិលមិញ មានអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អំពីបញ្ហា ប្រឈមនានានៅតាមឃុំ មានការលំបាកបែបណាអស់ហើយ ។ ក្នុងពេលតែមួយមានវគ្គបណ្តុះបណ្តាលនានាធ្វើក្នុងពេលតែមួយ ហើយឥឡូវមេភូមិ និងជំនួយការមេភូមិ ដែលទើបជាប់ឆ្នោតថ្មី មិនទាន់បានធ្វើការបណ្តុះបណ្តាលផង ដោយសារមានវគ្គនានាច្រើនពេក ទាំងថ្នាក់ជាតិ សីលា ថ្នាក់ខេត្ត និងមន្ទីរជំនាញទាំងអស់ មានការមមាញឹកដែលចេះតែចោទជាបញ្ហា ។ មេភូមិ និងជំនួយការមេភូមិ ដែលមិនទាន់បានធ្វើការបណ្តុះបណ្តាល នឹងមាន ការបណ្តុះបណ្តាលជាបន្ទាប់ទៀត ។ ទន្ទឹមនោះក៏មានសេចក្តីណែនាំពីក្រសួងមហាផ្ទៃ អភិបាល ដើម្បីធ្វើជាបន្ទាន់ ។ ឥឡូវកំពុងបញ្ជ្រៀតបណ្តុះបណ្តាលផ្នែកសុខាភិបាល និងសុខភាពសហគមន៍ ដើម្បីបង្រៀនដល់ក្រុមប្រឹក្សាឃុំ ។ ដូច្នេះ ការយឺតយ៉ាវនេះ សូមយោគយល់ពីការពិត និងកុំយល់ថាគេចែករំលង សូម្បីតែរូបលោកផ្ទាល់ និងបងប្អូន ក្រុមប្រឹក្សាឃុំខាងគណបក្សប្រជាជន មិនទាន់បានទទួលដូចគ្នា ។ លោកពេញចិត្តនឹងអ្វីដែលលើក ឡើងពីខាងដើម ដោយធ្វើយ៉ាងណាឱ្យបរិយាកាសបោះឆ្នោតប្រកបដោយសេរី ត្រឹមត្រូវ ដែលរដ្ឋាភិបាលកំពុងធ្វើការងារនេះ ម៉ត់ចត់ណាស់ មានការ គាំទ្រពិសេសខាងឯកឧត្តមអភិបាលខេត្ត អង្គភាពជំនាញ អាជ្ញាធរនានា ពិសេសការគាំទ្រលើគោលនយោបាយវិមជ្ឈការ ។ ការប្រជុំនេះមានសមាសភាពចំរុះមកពីគ្រប់គណបក្សទាំងអស់ និងអាជ្ញាធរនានាដែលដឹងពីការលំបាកនេះ លទ្ធផលជាតួលេខនេះមាន ៥៨.៣៨៣ប័ណ្ណ ទើបតែចែក បាន ២៤,៧៧% ដែលនេះយើងទទួលស្គាល់ទាំងអស់គ្នា ។ ក្រុមប្រឹក្សាឃុំបានធ្វើការងារនេះដោយប្រយ័ត្នប្រយែងណាស់ ។ ដោយសារខ្លាចខុស ទិន្នន័យនានា បានជា គជប និងរដ្ឋាភិបាល ចែកជូន ដើម្បីផ្ទៀង

ផ្ទាត់នៅពេលនេះ ។ សន្និសីទម៉្សិលមិញក៏បានសំណូមពរដែរថា ធ្វើម៉េចកុំឱ្យប៉ះពាល់ រយៈពេលនៃការចុះឈ្មោះ កុំឱ្យជាន់ទៅលើកម្មវិធី ដទៃទៀត ដើម្បីទុកលទ្ធភាពឱ្យស្មៀន ក្រុមប្រឹក្សាឃុំដែលទទួលបន្ទុកចែកប័ណ្ណព័ត៌មាន បានធ្វើការពេញលេញជាមួយពលរដ្ឋ ដោយមិនរើសអើងគណបក្សណាទេ គឺចែកឱ្យបានទាំងអស់គ្នា គឺគណបក្សទាំងអស់ដែលមានសិទ្ធិប្រលូកក្នុងការបោះឆ្នោត ដើម្បីឱ្យចំនួនអ្នកបោះឆ្នោតកើនឡើង និងដើម្បីឱ្យដំណើរការបោះឆ្នោតប្រកបដោយលក្ខណៈប្រជាធិបតេយ្យ សេរីពហុបក្ស តម្លាភាព និងយុត្តិធម៌ ។

លោក**វីរៈសេនីយត្រី សួន សុខេន** នាយការិយាល័យសន្តិសុខ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង យោងតាមផែនការក្រសួងមហាផ្ទៃកំណត់ថា ត្រូវផ្តល់អត្តសញ្ញាណប័ណ្ណឱ្យពលរដ្ឋបានគ្រប់គ្នា ដើម្បីបង្កលក្ខណៈឱ្យពលរដ្ឋយើង ងាយស្រួលចូលរួមបោះឆ្នោត ។ ស្នងការយើងបានចាត់ជាក្រុម ចុះទៅតាមបណ្តាស្រុកទៅតាមកម្មវិធី ។ នៅកំពង់ឆ្នាំង បានសរុបចំនួនពលរដ្ឋដែលមិនទាន់ទទួល អត្តសញ្ញាណប័ណ្ណជាបណ្តោះអាសន្ន ៣១.២៨១នាក់ ។ សកម្មភាពនេះ កំពុងបន្តធ្វើជាបន្តបន្ទាប់ ។ ចំពោះការយឺត ដោយសារមានបញ្ហានានា ដូចតទៅ ។ ប្រជាជនភាគច្រើន ពិសេសនៅតាមតំបន់ជនបទ មិនសូវយល់ពីរឿងនេះ ។ អ្នកដែលត្រូវការធ្វើអត្តសញ្ញាណប័ណ្ណ លុះណាតែមានតំរូវពី ធ្វើការងារនានា ដូចជា ទៅធ្វើការនៅតាមរោងចក្រ ។ លោកបានសំណូមពរដល់លោកមេភូមិ ឃុំ ជួយពន្យល់រឿងនេះ ដល់ប្រជាជនទាំងអស់នោះ ផង ។ មួយទៀត ពលរដ្ឋយើងច្រើនទៅរកស៊ីនៅតាមតំបន់ឆ្ងាយៗ នៅកំពង់ឆ្នាំងច្រើនប្រកបរបរនេសាទត្រី កាប់ឈើ ទៅធ្វើស្រែស្នាក់នៅទីនោះតែ ម្តង ដូចនេះក្រុមការងារ សូម្បី អាជ្ញាធរដែនដីក៏មិនអាចទៅរកពួកគាត់ឃើញដែរ ។ ឯខ្លះទៀតទៅក្រៅប្រទេស គឺសំដៅប្រទេសថៃ ដែលទៅក្រៅ ផ្លូវការ/ខុសច្បាប់ ដោយគ្មានអត្តសញ្ញាណប័ណ្ណ ទោះជាផ្នែកនគរបាលទប់ស្កាត់យ៉ាងណាក៏ដោយ ។ ពលរដ្ឋមួយចំនួនផ្លាស់ប្តូរទីលំនៅ និងអ្នកដែល ត្រូវសិក្សានៅភ្នំពេញ ។ ក្រុមការងារលោកធ្វើការងារនេះ ដោយមិនគិតថ្ងៃអាទិត្យទេ ដោយសារអ្នកដែលត្រូវសិក្សានៅភ្នំពេញអាចមកធ្វើ អត្តសញ្ញាណប័ណ្ណបាននៅថ្ងៃសៅរ៍ អាទិត្យ ។ នេះជាកត្តាមួយចំនួននៃការយឺតក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណដល់ពលរដ្ឋ ។ ចំនួននៅសល់នេះ នឹងអាចបញ្ចប់បានទៅតាមផែនការ ។

លោកវាគ្មិនខ្លះថា មានភ្នាក់ងារនគរបាលខ្លះយកលុយពីពលរដ្ឋដែលធ្វើអត្តសញ្ញាណប័ណ្ណ ។ លោកបញ្ជាក់ថា ជាគោលការណ៍របស់ក្រសួងមហាផ្ទៃ គឺមិនយកលុយពីពលរដ្ឋណាទេ ទាំងសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណ ។ បើមានភ្នាក់ងារនគរបាលណាយកលុយពីពលរដ្ឋ សូមផ្តល់ឈ្មោះមកស្នងការដ្ឋានដើម្បីដោះស្រាយ ។

លោក**ស្រី នួន ចន្ទី** ប្រធានលេខាធិការដ្ឋាន គជបខ សូមជំរាបជូនអង្គប្រជុំពីបញ្ហាផ្តល់ប័ណ្ណព័ត៌មានបោះឆ្នោត គឺប័ណ្ណនេះមិនអាចយកទៅប្រើក្នុងការបោះឆ្នោតបានទេ ។ ប័ណ្ណព័ត៌មានបោះឆ្នោតដែល ផ្តល់ជូនតាមបណ្តាឃុំនេះ គឺចាប់ផ្តល់ពីថ្ងៃ ១-៣១ សីហា ២០០៦ ។ បើក្រោយពីថ្ងៃនេះ បើមិនទាន់ទទួលប័ណ្ណនេះទេ សូមអញ្ជើមកទទួលនៅសាលា ឃុំ ក្រោយពីបានចុះតាមភូមិរួច ដែលបានរៀបចំតាមកម្មវិធីត្រឹមត្រូវ ពិសេសតំណាង គណបក្សនៅតាមស្រុក ដូចជា លោកស្រី គី សុភាព លោក ប៉ុល ទិតធានី ទាំងអស់គ្នាបានចូលរួមផ្សព្វផ្សាយការផ្តល់ប័ណ្ណព័ត៌មានបោះឆ្នោតនេះ ។ ការបោះឆ្នោតនៅឆ្នាំ២០០៧ ប្រើតែអត្តសញ្ញាណប័ណ្ណ និងប័ណ្ណ ជាផ្លូវការណាមួយ ដូចជា ប័ណ្ណសំគាល់មន្ត្រីរាជការ ។ បើលោកមិនបានទទួលប័ណ្ណព័ត៌មានបោះឆ្នោត និងមិនមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតទេ នៅថ្ងៃចុះឈ្មោះជាផ្លូវការខាងមុខ សូមអញ្ជើញទៅចុះឈ្មោះថ្មី ។ រឿងស្មៀនឃុំយកលុយ ពេលចុះឈ្មោះឆ្នោត សូមបញ្ជាក់ថា គជប មិនអនុញ្ញាត ឱ្យស្មៀនយកលុយទេ បើមានសូមរាយការណ៍ឱ្យច្បាស់ ជាពិសេសនៅឃុំច្រែស បើសិនជមានមែន ដើម្បីយើងខ្ញុំមានវិធានការដោយសហការជាមួយ អាជ្ញាធរ គឺអភិបាលខេត្ត ស្រុក ឃុំ ដើម្បីចាត់ការលើស្មៀនដែលយកលុយ ។

ទាក់ទងនឹងទំរង់ ១០១៨ ដែលមានបិទរូបថត ។ លោកស្រីបានបញ្ជាក់ថា នេះជាបញ្ហាមួយដែលពិបាកនៅតាមតំបន់ជនបទ តែនៅតាមទីរួមខេត្តមិនមានបញ្ហាច្រើនទេ ប៉ុន្តែនេះជានីតិវិធីរបស់ គជប បានកំនត់ ។ ទំរង់ ១០១៨ ដែលមិនមែនឆ្នាំបោះឆ្នោត មិនចាំបាច់បិទរូបថតទេ បើមានសាក្សីពីរនាក់ តែសំរាប់ឆ្នាំបោះឆ្នោត ចាំបាច់ត្រូវតែមានបិទរូបថត ព្រោះវាបញ្ជាក់នូវអត្តសញ្ញាណរបស់ខ្លួន ។

ចំពោះការផ្តល់ប័ណ្ណពត៌មានបោះឆ្នោតយឺត នេះក៏ជាបញ្ហាលំបាកដែរ ត្រឹមត្រូវណាស់ដែលលោកខាងដើមលើកឡើងថា សៀវភៅគ្រួសារឈ្មោះផ្សេង អត្តសញ្ញាណប័ណ្ណផ្សេង បញ្ជីបោះឆ្នោតផ្សេង លោកស្រីបានសាកល្បងនៅឃុំកោះថ្កូវ សង្កេតឃើញថា នាមត្រកូលអ្នកបោះឆ្នោតគឺផ្សេងៗគ្នា ឧទាហរណ៍ នៅក្នុងបញ្ជីបោះឆ្នោតឈ្មោះ សន យ៉ាន សន យ៉ា សន យឿន តែនៅក្នុងអត្តសញ្ញាណប័ណ្ណឈ្មោះ ខឹម យ៉ាន ខឹម យ៉ា ខឹម យឿន ដោយផ្អែកតាមអត្តសញ្ញាណប័ណ្ណរកមិនឃើញទេ ។ តាមការផ្លាស់ប្តូរនាមត្រកូលនេះ ដែលធ្វើឱ្យយើងពិបាក ។ លោកស្រីបញ្ជាក់ថា សំរាប់ការងារបោះឆ្នោត យើងយកអត្តសញ្ញាណប័ណ្ណជាគោល ។

**លោក ឱក សេរី សោភក្តិ** មុននឹងចាប់ផ្តើម លោកបានស្នើទៅអង្គប្រជុំឱ្យបិទទូរស័ព្ទ ដើម្បីកុំឱ្យរំខានដល់ការពិភាក្សា និងសូមជជែកដោយស្ងៀមស្ងាត់ នៅពេលអង្គប្រជុំកំពុង ដំណើរការ ដើម្បីកុំឱ្យវាគ្មិនបែកអារម្មណ៍ ។ លោកអញ្ជើញលោក Denis ជំនាញផ្នែកបច្ចេកទេសនៅ គជប និងជាសមាជិករបស់ UNDP នឹងមានប្រសាសន៍បញ្ជាក់ចំណុចខ្លះ ដោយលោកបានដឹងរឿងនានាច្រើនទាក់ទិននឹងការងារបោះឆ្នោត ។ បន្ទាប់ មកទៀតនឹងជូនប្រសាសន៍ទៅលោក សៀក គឹមលៀង នាយខុទ្ទកាល័យសាលាខេត្ត ក្នុងនាមតំណាងអភិបាលខេត្ត នឹងបញ្ជាក់លើបញ្ហានានាទាក់ទិននឹងការងារបោះឆ្នោតនៅកំពង់ឆ្នាំងនេះដែរ ។

**លោក Denis Truessell ជំនាញផ្នែកបច្ចេកទេសនៅ គជប** លោកធ្វើការជាជំនួយបច្ចេកទេសផ្នែករៀបចំការបោះឆ្នោតនៅ គជប ។ ប្រសាសន៍របស់លោកនៅពេលនេះ គឺក្នុងនាមជាអ្នកនាំសារពី គជប អំពីការផ្តួចផ្តើមគំនិតចែកប័ណ្ណពត៌មានអ្នកបោះឆ្នោតដែលកំពុងធ្វើនៅឆ្នាំនេះ ។ ជារៀងរាល់ពេលដែលមានការរៀបចំបញ្ជីចុះឈ្មោះអ្នកបោះឆ្នោត និងប័ណ្ណបោះឆ្នោតនៅខែតុលា និងស្នើឱ្យ គជប ផ្សព្វផ្សាយពត៌មានដល់ពលរដ្ឋដើម្បីអញ្ជើញអ្នកបោះឆ្នោតពិនិត្យឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីអ្នកបោះឆ្នោត ដើម្បីមកចុះឈ្មោះថ្មី បើមិនទាន់មានឈ្មោះនៅក្នុងបញ្ជីទេ និងដើម្បីបញ្ជាក់ ថាតើឈ្មោះដែលមាននោះត្រឹមត្រូវឬយ៉ាងណា ។ គជប ក៏ជំរុញទៅដល់គណបក្សនយោបាយទាំងអស់ ឱ្យប្រមូលអ្នកគាំទ្ររបស់ខ្លួន ដើម្បីមកពិនិត្យ និងចុះឈ្មោះថ្មី ។ ជាអកុសល កន្លងមកយើងទទួលបានលទ្ធផលមិនគួរ ជាទីពេញចិត្តឡើយ ព្រោះពលរដ្ឋមិនបានមកពិនិត្យតាមអ្វីដែល គជប ចង់បានទេ ។ ជាបទពិសោធន៍ គជប បានផ្តល់ឱកាសដល់ពលរដ្ឋ ដើម្បីឱ្យមក ពិនិត្យឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត និងអាចកែតំរូវ បើមានចំណុចខ្វះខាត ។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំនឹងប្រព្រឹត្តទៅនៅថ្ងៃ ០១ មេសា ២០០៧ ហើយ គជប រំពឹងថា ពលរដ្ឋទាំងអស់ នឹងមកពិនិត្យឈ្មោះរបស់ខ្លួនទាំងអស់គ្នា បើសិនពលរដ្ឋមិនមកពិនិត្យឈ្មោះរបស់ខ្លួនទេ គជប នឹងយកបញ្ជី នោះទៅបិទផ្សាយជាផ្លូវការ ។ តាមពិតទៅ ប័ណ្ណពត៌មានអ្នកបោះឆ្នោត គឺជាឈ្មោះរបស់អ្នកបោះឆ្នោត ដូចនៅក្នុងបញ្ជីអ្នកបោះឆ្នោតដែរ ដោយគ្រាន់តែចម្លងចេញពីបញ្ជីនោះទៅចែកជូនពលរដ្ឋទាំងអស់ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ទៅតាមអត្តសញ្ញាណប័ណ្ណ ។ បើពលរដ្ឋណាមានឈ្មោះ នៅក្នុងបញ្ជីអ្នកបោះឆ្នោតឆ្នាំ២០០៥ នោះឈ្មោះនៅក្នុងប័ណ្ណពត៌មានអ្នកបោះឆ្នោតក៏ដូច្នោះដែរ ។ បើពលរដ្ឋណាមិនមានឈ្មោះនៅក្នុងបញ្ជីអ្នកបោះ ឆ្នោតឆ្នាំ២០០៥ទេ ពួកគេនឹងមិនបានទទួលប័ណ្ណពត៌មានអ្នកបោះឆ្នោតទេ ដូច្នេះហើយបានជា គជប ត្រៀមថា នៅពេលចុះឈ្មោះបោះឆ្នោតនៅ ឆ្នាំ២០០៦ នេះហើយ នឹងផ្តល់ជូនប័ណ្ណពត៌មានមួយបន្ថែមទៀតនៅពេលមានការបោះឆ្នោតឃុំឆ្នាំក្រោយនេះ ។ អ្នកដែលទើបគ្រប់អាយុ ១៨ឆ្នាំ ហើយមិនបានទៅចុះឈ្មោះ ក៏មិនបានទទួលប័ណ្ណពត៌មានអ្នកបោះឆ្នោតនេះដែរ ។ គោលបំណងនៃការចែកប័ណ្ណពត៌មានអ្នកបោះឆ្នោត គឺដើម្បីជំរុញឱ្យ ពលរដ្ឋ ពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យនានារបស់ខ្លួនឡើងវិញ ប័ណ្ណនេះមិនប្រើប្រាស់សំរាប់គោលបំណងអ្វីផ្សេងទៀតទេ ។

បញ្ហាដែលកើតឡើងនោះ គឺការចែកចាយប័ណ្ណពត៌មានអ្នកបោះឆ្នោតនេះ ។ ក្នុងដំណាក់កាលនេះ គជប គ្មានជំរើសណា ក្រៅពីប្រើប្រាស់ធនធានដែលមានស្រាប់នោះទេ គឺតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រធានភូមិ ។ ប័ណ្ណពត៌មានអ្នកបោះឆ្នោត ជាឯកសារសាធារណៈ មិនមានអ្វីលាក់បាំងទេ ដើម្បីឱ្យគ្រប់គណបក្សនយោបាយទាំងអស់ អង្គការសង្គមស៊ីវិល ជួយក្នុងការចែកចាយដែរ ។ ជាការពិត វាអាចមានបញ្ហាក្នុងការចែក

ចាយនោះមែន ។ ក្នុងខ្លឹមសារមួយដែលលោកចង់ជំរាបជូនគឺ បើពលរដ្ឋណាមិនទាន់ទទួលបានប័ណ្ណពតិមានអ្នកបោះឆ្នោតនេះទេ គ្មានបញ្ហាអ្វីទេ ដោយគ្រាន់តែទៅពិនិត្យនៅក្នុងបញ្ជីបោះឆ្នោតដែលរក្សាទុកនៅស្នាក់ការឃុំដោយខ្លួនឯងប៉ុណ្ណោះ ។ ជារៀងរាល់ឆ្នាំបញ្ជីអ្នកបោះឆ្នោត នៅគ្រប់ស្នាក់ការឃុំទាំងអស់ មានបិទផ្សាយនៅថ្ងៃ ២៩ កញ្ញា ។ បើលោកអ្នកចង់ច្បាស់ថាមានឈ្មោះនៅក្នុងញ្ជីអ្នកបោះឆ្នោតនោះត្រឹមត្រូវឬយ៉ាងណា សូមអញ្ជើញទៅពិនិត្យដោយខ្លួនឯង លោកអ្នកនៅមានពេលធ្វើការកែតំរូវ បើមានទិន្នន័យណាមួយមិនត្រឹមត្រូវ និងអាចចុះឈ្មោះថ្មីបាន ។ ដើម្បីបញ្ជាក់ពីរឿងនេះ គជប បានចេញសេចក្តីប្រកាសមួយដើម្បីជូនដំណឹងទៅអ្នកបោះឆ្នោតទាំងអស់ ។ ទាក់ទងនឹងពតិមាននេះ លោកបានយកមកជាមួយចំនួន ៤0ច្បាប់ដែរ ។ ពតិមានទាំងអស់នេះ នឹងផ្សព្វផ្សាយជូននៅតាមទំព័រសារពតិមានជាភាសាខ្មែរនានាចាប់ពីថ្ងៃនេះ ដល់សប្តាហ៍ក្រោយ ។ នៅតាមខេត្តខ្លះ ប្រហែលជាសាពតិមានមិនបានទៅដល់ និងមិនបានជ្រាបពីរឿងនេះច្រើនទេ ហេតុនេះបានជា គជប នឹងធ្វើការផ្សព្វផ្សាយនៅតាមស្ថានីយទូរទស្សន៍ វិទ្យុ និងប័ណ្ណប្រកាសនានាថែមទៀតអំពីបញ្ហានានាដែលទាក់ទងនឹងការចែកប័ណ្ណពតិមានអ្នកបោះឆ្នោតនេះ ។

**លោក ឱក សេរី សោភក្តិ៍** ដូច្នេះយើងទាំងអស់គ្នា បានទទួលការបញ្ជាក់នានាជុំវិការចែកប័ណ្ណពតិមានអ្នកបោះឆ្នោតនេះ ។ លោកបានមើលឃើញ ចំណុចមួយទៀត គឺ គជប មិនអាចចែកចាយដោយខ្លួនឯងផ្ទាល់បានទេ ដោយសារគ្មានរចនាសម្ព័ន្ធជាប់នឹងពលរដ្ឋ ដូច្នេះត្រូវតែឆ្លងកាត់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមេភូមិដែល ទើបជាប់ឆ្នោតថ្មី ។ ការចែកចាយនេះជាឱកាសល្អមួយថ្មីសំរាប់មេភូមិ ដើម្បីបង្ហាញពីភាពច្បាស់លាស់ និងសច្ចះធមិរបស់ខ្លួនក្នុងការបំពេញការងារ នោះនឹងទទួលបានកិត្តិយសពីការងាររបស់ខ្លួន ដែលបង្កើតឱ្យមានទំនុកចិត្តពីគ្រប់គណបក្ស និងពលរដ្ឋទាំងអស់ ។

លោក **សៀក គឹមលៀង** នាយខុទ្ទកាល័យ ខេត្តកំពង់ឆ្នាំង លោកចាប់អារម្មណ៍បន្ថែមទៅលើកិច្ចសហប្រតិបត្តិការទទួលខុសត្រូវកន្លងទៅរបស់អ្នកដឹកនាំខេត្ត ដែលមាន គជបខ ដោយបានទទួលការងារចែកប័ណ្ណពតិមានអ្នកបោះឆ្នោតនៅចុងខែកក្កដាពី គជប ដោយប្រញាប់ប្រញាល់ ។ អាជ្ញាធរខេត្តបានធ្វើការងារជាបន្ទាន់ ដោយចែកឱ្យបានទៅដល់ស្រុក ឃុំ ភូមិ ឱ្យទាន់ពេលវេលា ។ លោកសរសើរ ដល់លោកស្រីប្រធានលេខាធិការដ្ឋាន ចំពោះការងារដ៏សកម្មរបស់លោកស្រីក្នុងការចែកប័ណ្ណពតិមានអ្នកបោះឆ្នោតនេះ ដោយលោកស្រីបានចុះទៅតាមស្រុកនានាដោយផ្ទាល់ ។ តាមការណែនាំរបស់ គជប គឺអញ្ជើញតែមេឃុំទេ ដើម្បីមកធ្វើការណែនាំ អំពីការចែក ហើយមេឃុំយកទៅផ្សព្វផ្សាយបន្តទៅសមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកម្នាក់ និងមេភូមិគ្រប់ភូមិទាំងអស់ ។ លោកក៏បានស្នើឱ្យ មានអភិបាល និងអភិបាលរងស្រុកបន្ថែមទៀត និងតំណាងគណបក្ស អង្គការសង្គមស៊ីវិលនានាតាមស្រុក ឱ្យមកចូលរួមស្តាប់ក្នុងកិច្ចប្រជុំដំបូងដែរ ។

ដូច្នេះដំណើរការផ្សព្វផ្សាយ និងចែកប័ណ្ណពតិមានអ្នកបោះឆ្នោត អាចប្រព្រឹត្តទៅដោយបែងចែកទៅតាមតារាងពេលកំណត់ និងដើម្បីទទួលបានពតិមានត្រលប់មកវិញពីលោកអភិបាល អភិបាលរងស្រុក និងមេឃុំ អំពីការចែកចាយបានដល់ក៏រិតណា ចែកផ្ទាល់បានប៉ុន្មាននាក់ តាមរយះតំណាងបានប៉ុន្មាននាក់ រកឃើញអ្នកត្រូវលុប អ្នកផ្លាស់ចេញ យើងបានរាយការណ៍ជូន គជបខ រាល់ថ្ងៃសុក្រ ។ លោកពិនិត្យឃើញថា មានវត្តមានលោកអភិបាល អភិបាលរងគ្រប់ទាំង ៨ ស្រុក និងក្រុមប្រឹក្សាឃុំ លោកបានស្នើសុំឱ្យជួយចែកប័ណ្ណពតិមានអ្នកបោះឆ្នោតនេះ ឱ្យដល់ពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទាំងអស់គ្នា ឱ្យត្រឹមត្រូវ នៅពេលត្រលប់ទៅវិញ ។ ដើម្បីជៀសវាងកំហុសឆ្គង អស់លោកត្រូវធ្វើតាមនីតិវិធី គឺចែកផ្ទាល់ដៃ និងតាមរយះតំណាង ឧទាហរណ៍ ជូនលោក បុណ្យ ផ្ទាល់ដៃ ប្រពន្ធនិងកូនដែលមានឈ្មោះក្នុងបញ្ជី គឺហៅថាតាមរយះតំណាង មិនមែនឱ្យទៅមេភូមិមួយបាច់ ជូនអ្នកនេះ អ្នកនោះតគ្នាទេ មិនមែនឱ្យមេបក្សនានានៅស្រុកកាន់មួយបាច់ទៅចែកតគ្នាទេ ធ្វើបែបនេះនឹងខុសនីតិវិធី ។ ដូច្នេះសង្ឃឹមថា អស់លោកបានយល់ច្បាស់ហើយនៅពេលដែលទាំងអស់គ្នាបានចូលរួមប្រជុំ បើមានបញ្ហា ត្រូវស្រូតទំនាក់ទំនងជាមួយឃុំ ហេតុអ្វីបានជាការចែកប័ណ្ណពតិមានអ្នកបោះឆ្នោតនេះយឺត? លោកយល់ថាទាំងអស់គ្នា សុទ្ធតែជាប់ស្ទូងទាំងអស់គ្នា ។ រហូតមកដល់ពេលនេះ បានប្រព្រឹត្តទៅ ១៧ថ្ងៃហើយ ដូច្នេះតាមកម្មវិធីនៅសល់ ១១ថ្ងៃទៀត គឺផុតកំណត់នៅថ្ងៃ ៣១ សីហា ។ ដូចលោកខាងដើមមានប្រសាសន៍ដែរ ប័ណ្ណពតិមានអ្នក

បោះឆ្នោតនេះ គឺគ្រាន់តែជាពតិមានទេ បើកទូលាយឱ្យបានជ្រាប ហើយមិនទាន់បានទទួលប័ណ្ណ នៅថ្ងៃ ២៩ កញ្ញា ក៏នៅតែមានឱកាសទៅកែ និងចុះឈ្មោះថ្មីដែរ ព្រមទាំងនៅពេលបិទបញ្ជីអ្នកបោះឆ្នោត ក៏អាចទៅមើល និងកែតំរូវបានដែរ ។ ដូច្នេះអ្នកដែលគ្មានឈ្មោះ និងទើបដល់អាយុបោះឆ្នោតត្រូវរូតរះទៅចុះឈ្មោះក្នុងអំឡុងថ្ងៃ ១-២០ តុលា ២០០៦ តោងតែយល់ដឹង និងជួយជំរុញឱ្យការងារនេះដំណើរការទៅមុខដោយរលូន ។ ដូច្នេះការចែកប័ណ្ណពតិមានអ្នកបោះឆ្នោត ហាក់ដូចជាមិនមានអ្វីគួរឱ្យពិបាកដល់លោកអភិបាល និងអភិបាលរងស្រុក សូមជួយជំរុញ មេឃុំ និងមេភូមិឱ្យចែកទៅដល់ដៃ និងតាមតំណាងដ៏ត្រឹមត្រូវ ឱ្យគ្រប់គ្នា និងរហ័ស ហើយសូមកុំមានមន្ទិលសង្ស័យថា ចែកតែបក្សនេះមិនចែកឱ្យបក្សនោះ ដើម្បីឱ្យពលរដ្ឋដែលមានឈ្មោះត្រឹមត្រូវហើយឆាប់បានចូលបោះ នឹងអាលត្រលប់មកផ្ទះវិញ ។

ឯទំរង់ ១០១៨ ត្រូវតែមានបិទរូបថត ដើម្បីបញ្ជាក់អត្តសញ្ញាណអ្នកកាន់ បើមិនបិទរូបថតទេ អ្នកណាក៏អាចកាន់ទៅបោះឆ្នោតបានដែរពិតហើយ វានឹងធ្វើឱ្យប្រជាជនចំណាយលុយអស់ ៣.០០០៛ ថតរូប ចំពោះសៀវភៅគ្រួសារមានរូបថតតែមេគ្រួសារ ដូច្នេះសមាជិកនៅក្នុងនោះគ្មានរូបថតទេ មិនមានអត្តសញ្ញាណបញ្ជាក់ទេ ។ បើមិនអនុវត្តតាមនីតិវិធីនេះ នឹងអាចបង្កជាបញ្ហានានានៅពេលបោះឆ្នោត ដូចជា អាចនឹងមានគេបន្លំទៅបោះឆ្នោតជំនួស ជាដើម ។ ដូច្នេះសូមឱ្យមានការយោគយល់ចំពោះការធ្វើទំរង់ ១០១៨ នេះ ព្រោះអ្នកដែលនឹងត្រូវធ្វើទំរង់ ១០១៨ មានតិចនាក់ដែរទេ ។ ដើម្បីជៀសវាងធ្វើទំរង់ ១០១៨ នៅពេលគេឱ្យទៅពិនិត្យ និងចុះឈ្មោះ ត្រូវទៅតាមការកំណត់ នឹងមិនមានការចំណាយអ្វីទាំងអស់តាំងពីមុនរហូតដល់ពេលនេះ ។

នៅទីបញ្ចប់ លោកនាយខុទ្ទកាល័យញ្ជាក់ថា ចំពោះការដែលចោទថា មានស្មៀន និងមន្ត្រីប៉ូលីស យកលុយនៅពេលពលរដ្ឋទៅធ្វើអត្តសញ្ញាណប័ណ្ណនោះ សូមរាយការណ៏ និងរៀបចំជាឯកសារឱ្យបានច្បាស់អំពីពេលវេលា ទីកន្លែង លោកណាជាអ្នកប្រព្រឹត្ត ។ បើករណីនេះពិតមែនថ្នាក់ដឹកនាំខេត្ត នឹងមិនអនុគ្រោះដល់ជននោះទេ ។

លោក **អ៊ុង ឡឿន** អភិបាលរងស្រុកទឹកផុស លោកមាន ៥ ចំណុចទាក់ទងនឹងរបៀបគ្រប់គ្រង ដឹកនាំ និងការចាត់តាំងសកម្មភាពរបស់ស្រុកទឹកផុស ។ ទី១ លោកសង្កេតឃើញថា ដូចលោក លោកស្រីជ្រាបហើយ ពលរដ្ឋមិនចូលរួមចំណែកជាមួយនឹងសកម្មភាពនានារបស់យើងទេ ដោយសារមាន ការនឿយហត់នឹងការងារស្រែចំការ និង ជីវភាពរស់នៅ តែយើងមាននាទីលើកកំពស់ការយល់ដឹងរបស់ពួកគាត់ឱ្យយល់ពីកាតព្វកិច្ចរបស់ខ្លួនដែលមិន អាចខកខានបាន ។ យើងបានជូនដំណឹង ថា ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតគឺចាប់ពីថ្ងៃ ០១ មករា ដល់ ៣០ កញ្ញា ពី ០១-២០ តុលា មិនទៅ ចុះឈ្មោះ និងមិនរវើរវល់ពីរឿងនេះទេ ដែល នេះជាការងារលំបាករបស់យើងខ្ញុំ ។ ទី២ អំពីការគ្រប់គ្រងប្រជាជន ។ បើយើងមិនផ្តល់អាទិភាពដល់ មេភូមិ អនុភូមិ លេខាភូមិ គ្រប់គ្រង តើធ្វើម៉េច គាត់ដឹងអ្នកចេញចូល អ្នកស្លាប់ និងដឹងពីអ្នកគ្រប់អាយុបោះឆ្នោត ១៨ឆ្នាំឡើង ដូច្នេះអ្វីៗទាំងអស់ ធ្លាក់មកលើភូមិ ហើយទាក់ទងដល់ការសរសេរ អក្សរ អក្ខរាវិរុទ្ធ អត្រានុកូលដ្ឋាន ។ ចំពោះប៉ុស្តិ៍នគរបាលរដ្ឋបាល នៅពេលការធ្វើអត្តសញ្ញាណប័ណ្ណ ក៏ទៅយកឈ្មោះ/ទិន្នន័យពីភូមិដែរ ដូច្នេះសូម សហការសរសេរអក្ខរាវិរុទ្ធឱ្យបានត្រឹមត្រូវ ដែលនេះជាការទទួលខុសត្រូវរួម ។ ចំពោះសមត្ថភាព ការងារ គឺទាក់ទងនឹងសុខភាព អត្តចរិត និងគុណធម៌ ។ ទី៣ ទាក់ទិននឹងងការផ្សព្វផ្សាយ ដូចលោកទីប្រឹក្សា គជប ដែលបញ្ជាក់ពីការផ្សព្វផ្សាយ ជាយោបល់ផ្ទាល់ខ្លួន លោកយល់ថា ជួនកាលពលរដ្ឋ ស្តាប់បាន និងស្តាប់មិនបាន ព្រមទាំងខ្វះកាតព្វកិច្ច និងករណីយកិច្ច និងការគោរពច្បាប់ គឺគ្រាន់តែលឺ តែមិនបានចូលរួម ។ លោកសំណូមពរថា បើមានកាសែ្សតពាក់ព័ន្ធនឹងការងារបោះឆ្នោតជាការល្អ ដើម្បីផ្តល់ដំណឹងតាមមីក្រូ ដល់ប្រជាពលរដ្ឋនៅក្នុងភូមិ និងនៅតាមវត្ត ដើម្បីឱ្យយល់ពីកាតព្វកិច្ច និងករណីយកិច្ចរបស់ខ្លួនជាពលរដ្ឋ ។ ដោយខ្វះខាតថវិកាក្នុងការបំពេញ ភារកិច្ចដូចជា ប៉ូលីសចុះទៅធ្វើអត្តសញ្ញាណប័ណ្ណ បើមិនជួយ ធ្វើម៉េចកើត ។ ទី ៤ អំពីការងារស្មៀន មានច្រើនពេកនៅមូលដ្ឋាន កុំអោបការងារ ច្រើនពេកសុំធ្វើការនីមួយៗឱ្យស្រេចបាច់សិន ចាំចាប់ផ្តើមការងារថ្មីទៀត ។ យើងទាំងអស់គ្នាជាអ្នកដឹកនាំ ត្រូវបង្វែរមុខព្រួញឆ្ពោះទៅមូលដ្ឋាន ដើម្បីបង្កើនការចូលរួមរបស់ពលរដ្ឋ ។

**លោក ឱក សេរី សោភក្តិ៍** នៅខេត្តបាត់ដំបង គេស្នើឡើងថា សុំឱ្យ គជបខ ទាក់ទងវត្តអារាម (នៅស្រុកយើងមានវត្តច្រើន វត្តនីមួយៗមានមីក្រូ និងអាគុយ ដែលតែងមាន ធ្វើបុណ្យជាប់) សង្គមស៊ីវិល ដែលមានការចូលរួមពីសំណាក់គណបក្សទាំង ៣ និងលោកចៅអធិការវត្ត ឱ្យចាក់ផ្សាយ ពត៌មាននានាទាក់ទងនឹងការ បោះឆ្នោត ។ អង្គប្រជុំបានឯកភាពតាមសំណើនោះ ហើយជាគំនិតផ្ទាល់ លោកបានលើកឡើងថា យើងមានសិស្សានុសិស្សច្រើននៅតាមសាលារៀន ដែលស្ម័គ្រចិត្តជួយការងារមេភូមិ បើយើងសម្លឹងមើលប្រភពធនធានដែលមាននៅថ្នាក់មូលដ្ឋាន គជបខ គួរតែទាក់ទងជាមួយអនុវិទ្យាល័យ វិទ្យាល័យ ដើម្បីឱ្យមានការចូលរួមពីអ្នកទាំងនោះ និងប្រើធនធានដែលមាននៅតាមមូលដ្ឋានឱ្យអស់លទ្ធភាព ។

**លោកស្រី គី សុភាព តំណាងគណបក្ស សម រង្ស៊ី** លោកស្រីយល់ថា ការចែកប័ណ្ណពត៌មានអ្នកបោះឆ្នោត មានសារៈសំខាន់ណាស់ ព្រោះបើមានទិន្នន័យខុស នឹងគ្មានសិទ្ធិបោះឆ្នោត ។ ពិតមែនតែយើង មិនយកប័ណ្ណនោះទៅបោះឆ្នោតទេ តែយកប័ណ្ណនេះទៅផ្ទៀងជាមួយអត្តសញ្ញាណប័ណ្ណ បើត្រូវទើបអាចបោះឆ្នោតបាន ។ ប័ណ្ណនេះបានចែកទៅ ដល់ភូមិ ពលរដ្ឋមិនរវល់នឹងវាផង ទំរាំឱ្យទៅផ្ទៀងនៅសាលាឃុំ គ្មានពេលទៅ ទេនោះនឹងគ្មានសិទ្ធិបោះឆ្នោតនៅពេលខាងមុខ ។

គជប នឹងចាត់តាំងជំនួយការម្នាក់ទៅប្រចាំការនៅស្ថានីយបោះឆ្នោត តើ គជប នឹងជ្រើសរើសយកអ្នកណាទៅបំរើការងារនេះ? លោកស្រីឱ្យជ្រើសយកជនឯករាជ្យណាម្នាក់ទៅបំរើការងារនោះ ដើម្បីឈរនៅកាវិយាល័យ ដែលមិនមែនជាមន្ត្រីរាជការដែលកំពុងកាន់អំណាចសព្វថ្ងៃនេះ អាចជ្រើសចេញពីអង្គការមិនមែនរដ្ឋាភិបាល ។ ចំពោះការដោះស្រាយពាក្យបណ្តឹងកន្លងមកនៅមិនទាន់ច្បាស់លាស់ និងមិនទាន់ពេលវេលា ជាក់ស្តែងនៅភូមិច្រកល្ហៀត ប្រធានភូមិច្រកល្ហៀតមកធ្វើជាអ្នកសង្កេតការបោះឆ្នោត ។ លោកស្រីបានធ្វើពាក្យបណ្តឹងមក គជបខ ដោយ គជបខ គ្រាន់តែធ្វើការព្រមានជាលាយលក្ខណ៍អក្សរ នេះទោសស្រាលពេក ដែលមានភាពអយុត្តិធមិសំរាប់គណបក្សនីមួយៗ និងចំពោះរាស្ត្រទូទៅ ។ លោកស្រីចង់បញ្ជាក់ជាមួយ គជប ឱ្យច្បាស់ និងសូមប្រាប់ទៅរាល់ គជបខ ទាំងអស់ថា ពាក្យបណ្តឹងទំរង់ ១២០៣ ទោះបានមកពីណាក៏ដោយ ត្រូវតែទទួលឱ្យតែត្រូវតាមទំរង់នោះ ។ អ្នកទទួលពាក្យបណ្តឹងតែងចោទថា ពាក្យបណ្តឹងនេះធ្វើមិនត្រឹមត្រូវទេ ដោយគ្មានអង្គហេតុអង្គច្បាប់ ដូច្នេះ សូមឱ្យ គជប ធ្វើសេចក្តីណែនាំឱ្យច្បាស់ពីវិធីធ្វើពាក្យបណ្តឹងដែលត្រូវ ដើម្បីកុំឱ្យចេះតែដោះសារ និងលេសនានា ។ សូមឱ្យមានលិខិតអញ្ជើញជាលាយលក្ខណ៏អក្សរក្នុងការចូលរួមចែកប័ណ្ណពត៌មានអ្នកបោះឆ្នោត ដល់គណបក្សនយោបាយនានាផង ដើម្បីជួយឱ្យពលរដ្ឋទទួលបានប័ណ្ណពត៌មានអ្នកបោះឆ្នោត ។ ជាចុងក្រោយលោកស្រីក៏បានបញ្ជាក់អំពីការការពារហិបឆ្នោតដែរ ដោយលើកឡើងថានៅតាមមណ្ឌលខ្លះគ្មានអគ្គិសនីបំភ្លឺទេនៅពេលសួរទៅមន្ត្រីបោះឆ្នោតថាគ្មានថវិកាសំរាប់ផ្នែកនេះ និងមិនគ្រប់គ្រាន់ទេ ។ ដូច្នេះដោះស្រាយបញ្ហានេះផង ។

**លោក ឱក សេរី សោភក្តិ៍** ដោយកិច្ចប្រជុំ ខប់សែល នៅថ្នាក់ជាតិ បានលើកជាច្រើនដង និងមានការស្នើសុំពីសង្គមស៊ីវិល ទាក់ទងនឹងការប្រើប្រាស់ទំរង់នានា គជប បានសំរេចថា ដើម្បីបំរើយន្តការបោះឆ្នោតនៅឆ្នាំ២០០៧ និង ២០០៨ នឹងលែងមានវគ្គបំពាក់បំប៉នដាច់ៗពីគ្នាហើយ គឺមន្ត្រី គជប គ្រប់លំដាប់ថ្នាក់ អ្នកសង្កេតការណ៏សង្គមស៊ីវិល និងភ្នាក់ងារគណបក្ស នឹងបើកវគ្គបំពាក់បំប៉នរួមគ្នាតែម្តង ដើម្បីឱ្យបានជ្រាបទាំងអស់គ្នា ហើយសង្គមស៊ីវិល និង ភ្នាក់ងារគណបក្ស ធ្វើការបំពាក់បំប៉នបន្ត ។ ធ្វើបែបនេះ នឹងបញ្ចៀសបាននូវបញ្ហាជាច្រើន ។

លោក **ហែម សម្ផស្ស** តំណាងគណបក្ស សម រង្ស៊ី ក្រោយពីបានស្តាប់វាគ្មិនខាងដើម ហាក់ដូចជាមានមតិស្រដៀងគ្នា ទាក់ទិននឹងការផ្តល់ប័ណ្ណពត៌មានអ្នកបោះឆ្នោត ។ ឃើញថាការផ្តល់ប័ណ្ណពត៌មាន អ្នកបោះឆ្នោត តាមផ្លូវច្បាប់បានល្អណាស់ ដើម្បីបង្កភាពងាយស្រួលក្នុងដំណើរការបោះឆ្នោត តែបើគិតឱ្យស៊ីជំរៅ គឺជាការបង្កការពិបាកបំផុតសំរាប់ ពលរដ្ឋ ។ ហេតុអ្វីបានជាចេះតែបង្កើតរឿងឱ្យចេះតែពិបាកទៅៗ និងនាំឱ្យពលរដ្ឋវង្វេងគ្រប់

ពេលវេលា ។ ពេលបោះឆ្នោតមកដល់តែងខុសឈ្មោះ ដូរទីតាំងការិយាល័យ ធ្វើឱ្យពលរដ្ឋរកមិនឃើញ នាំឱ្យមិនបានទៅបោះឆ្នោត ដូចជាឃុំខ្លះ គណបក្ស សម រង្ស៊ី ខ្វះ ២-៣សម្លេង នឹងបានជំទប់មួយ ។ ឥឡូវដល់រឿងការចែកប័ណ្ណពត៌មានអ្នកបោះឆ្នោត បើធ្វើដោយអចេតនា កំហុសអក្ខរាវិរុទ្ធ ថ្ងៃខែឆ្នាំកំណើត គឺយើងទទួលបាន តែហេតុអ្វីបានជា ខុសខ្លាំងម្លេះ តើអ្នកធ្វើខ្វះសមត្ថភាពឬយ៉ាងណា តែងតែខុសជានិច្ចទាំងអត្តសញ្ញាណប័ណ្ណ និងប័ណ្ណពត៌មានអ្នកបោះឆ្នោត តើមានពិនិត្យឬទេ ពេលធ្វើ ការនោះ ។ សិស្សប្រលងរាប់ម៉ឺននាក់មួយឆ្នាំៗ ខុសបច្ចេកទេស ១-២នាក់ទេ ឯឈ្មោះពលរដ្ឋធ្វើរាប់ឆ្នាំមកហើយ តែងតែខុសជានិច្ច ។ លោកបាន សំណូមពរដល់អង្គការសង្គមស៊ីវិលក្តី រាជរដ្ឋាភិបាល ជាពិសេស គជប សូមបង្កភាពងាយស្រួលគ្រប់បែបយ៉ាងដល់ពលរដ្ឋ ។ ហេតុអ្វីបានជាការបោះ ឆ្នោតសម័យអ៊ុនតាក់ថាល្អ ចុះឈ្មោះនៅទីណាក៏អាចបោះឆ្នោតបានដែរ ឥឡូវយ៉ាងម៉េចបានជាធ្វើឱ្យពលរដ្ឋវង្វេងវង្វាន់អស់ សូម្បីតែលោកផ្ទាល់ក៏ វង្វេងដែរ ។ ការពិតអស់លោកទទួលតែរបាយការណ៍ពត៌មានក្នុងអង្គប្រជុំ តែចុះទៅមូលដ្ឋានសាកមើល នឹងវង្វេងដែរ ហើយធ្វើចំពេលដែលពលរដ្ឋ កំពុងមមាញឹកស្ទូងក្នុងស្រែចំការ មិនព្រមធ្វើកាលពីពេលរាំងស្ងួត ។ ពលរដ្ឋមិនបានគិតស៊ីជំរៅទេថា សន្លឹកឆ្នោតមួយសន្លឹក ស្មើអាយុជីវិតគាត់ទេ ។ លោកសំណូមយ៉ាងទទូចថា សូមគ្រប់ស្ថាប័នជាតិ សង្គមស៊ីវិល គជប កែតំរូវធ្វើយ៉ាងណាឱ្យរាស្ត្រងាយស្រួលបំផុត ។

ចំពោះប័ណ្ណទាំង ១០ប្រភេទ មានអត្តសញ្ញាណប័ណ្ណ ប័ណ្ណសំគាល់មន្ត្រីរាជការ.... សូមសួរថា តើប័ណ្ណសំគាល់សិស្ស ប័ណ្ណសំគាល់កម្មករ / កម្មការិនី តាមក្រុមហ៊ុន រោងចក្រ ហេតុអ្វីបានជាមិនមានសិទ្ធិបោះឆ្នោតជាផ្លូវការផង? ព្រោះប័ណ្ណទាំងនេះ ទទួលស្គាល់ដោយរាជរដ្ឋាភិបាលដូចគ្នា ។ តើប័ណ្ណទាំងនេះមានលក្ខណៈខុសគ្នាយ៉ាងណា?

លោកបានចាប់អារម្មណ៍ថា អ្វីដែលមាននៅតាមមូលដ្ឋាន គឺមានពិតមែន គណបក្ស សម រង្ស៊ី មិនប្រឌិតឡើងទេ ។ សូម្បី គជប ប៉ូលីស រដ្ឋាភិបាល ក៏មានលម្អៀងដែរ មិនអព្យាក្រឹតទេ ប៉ុន្តែសូមឱ្យមានក៏រិតថាយើងអាចទទួលយកបានទាំងអស់គ្នា ។ លោកធ្លាប់បានដាក់បំរើការងារបោះឆ្នោតដែរ តែមិនត្រូវបានគេជ្រើសទេ សូម្បីនៅការិយាល័យតូចមួយ មិនចាំបាច់នៅថ្នាក់ គជបខ ទេ តែបែជាជាប់អ្នកគ្មានសមត្ថភាពវិញ ដែលបញ្ជាក់ថាធ្វើឱ្យមានខុសឈ្មោះ និងទិន្នន័យនានា ។ នៅពេលបោះឆ្នោត អភិបាលស្រុក អធិការប៉ូលីស មេឃុំ យកកាំភ្លើងមកភ្ជុង (ក្នុងអំឡុងពេលឃោសនាបោះឆ្នោត) ចាប់លោក ហើយលោកបានប្តឹងរាប់រយពាន់ករណី រហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញ គជប មិនដែលបានដោះស្រាយទេ ហើយទុកជាមោឃៈទាំងអស់ ។ លោកចង់ឱ្យដំណើរការបោះឆ្នោតមានតម្លាភាព និងយុត្តិធម៌ ។ លោកបានស្រាវជ្រាវដឹងអស់ហើយ ដូច្នេះនៅពេលមានពាក្យបណ្តឹង សូមដោះស្រាយឱ្យផង ។ ជម្ងឺគ្រុនចាញ់ ទំរាំរកថ្នាំព្យាបាលបាន ចំណាយរាប់រយឆ្នាំ តែនៅពេលឈឺយកថ្នាំនោះមកព្យាបាល ។ ប្រទេសនានា គេប្រជាធិបតេយ្យរាប់រយឆ្នាំហើយ យើងទើបតែរួចផុតពីសង្គ្រាម តែក្រោយពីសង្គ្រាមចាប់ដៃគ្នាអភិវឌ្ឍន៍ប្រទេស គណបក្សប្រឆាំង រិះគន់តែអ្វីដែលអាក្រក់ទេ យើងត្រូវទទួលស្គាល់ ឈើ ត្រី អស់ហើយ ដីអស់បន្តិចដែរហើយ ជាក់ស្តែងដីកម្ពុជាក្រោម ខ្មែរសុរិន្ទ ឥឡូវរដ្ឋាភិបាលទទួលស្គាល់អំពើពុករលួយ ធនាគារពិភពលោកក៏បានរកឃើញបញ្ហានេះដែរ ។ លោកអបអរសាទរអ្វីដែលរាជរដ្ឋាភិបាលធ្វើបាន ។ នៅទីបញ្ចប់លោកបានសំនូមពរថា សូមឱ្យដោះស្រាយនូវរាល់បណ្តឹងរបស់គណបក្សនយោបាយ ។

លោក **ឱក សេរី សោភក្តិ៍** អរគុណដល់តំណាងគណបក្ស សម រង្ស៊ី តែនេះជាឧទាហរណ៍ដែលសុំអនុញ្ញាតលោក លោកស្រីឯទៀតៗ សុំកុំឱ្យមានបែបនេះទៀត ព្រោះយើង និយាយតែរឿងបោះឆ្នោតបានហើយ តោងកុំយករឿងផ្សេងមកនិយាយ បើយករឿងផ្សេងមកនិយាយ កុំថា ៣ម៉ោង ៣០នាទី ទោះមួយថ្ងៃ ក៏មិនចប់ដែរ ។ លោកអរគុណដល់តំណាងគណបក្ស សមរង្ស៊ី ដែលលើកឡើងពីការឆ្គាំឆ្គងនានា អំពីការលំបាកនានាដែលពលរដ្ឋបានជួបប្រទះនៅ តាមមូលដ្ឋាន ខេត្តឯទៀតក៏មានដូចច្នោះដែរ អ្វីដែលលោកលើកឡើង គឺមានភាពជាក់ស្តែងមែន តែសុំកំរិតត្រឹមតែរឿងបោះឆ្នោតបានហើយ កុំងាកទៅវែងឆ្ងាយ ហើយម្នាក់សុំគោរពពេលវេលា ព្រោះកាលណាមិនគោរព អ្នកឯទៀតនឹងគ្មានឱកាសនិយាយបញ្ចេញយោបល់ ។

លោក **តាំ សារឿន** អភិបាលរងស្រុកកំពង់ត្រឡាច វាគ្មិននៅខាងដើម្បីបាននិយាយទាក់ទិននឹងភូមិឃុំដែលមាននៅមូលដ្ឋាលរបស់លោក គឺភូមិច្រកល្មៀត ឃុំប្រែស ស្រុកកំពង់ត្រឡាច ។ លោក បានបញ្ជាក់ដោយឆ្លើយតបនឹងប្រសាសន៍លោក កែវ ឆយ អំពីរឿងស្មៀន យកលុយកាក់ពីពលរដ្ឋ នៅពេលធ្វើឯកសារនានា ហើយស្មៀន គឺស្ថិតនៅ ក្រោមការគ្រប់គ្រងផ្ទាល់របស់មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំទាំងអស់ បើការខុសឆ្គង សូមលោកជាជំទប់សូមជួយណែនាំបន្ថែម ហើយមេភូមិយក លុយ ១០០៛ ពីពលរដ្ឋ សំរាប់សីមីមួយ ដែលគាត់ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំទាំងអស់ដែរ សូមលោកស្រាវ ជ្រាវពិនិត្យឡើងវិញ នេះការងារដែលទាក់ទងនឹងរដ្ឋបាល ។ ដើម្បីឆ្លើយតបនឹងមតិលោកស្រី គី សុភាព ដែលពាក់ព័ន្ធនឹងការចែកប័ណ្ណពតិមាន ។ ក្នុងនាមអាជ្ញាធរស្រុក បានរៀបចំផែនការចែកដោយប្រុងប្រយ័ត្ន ទៅតាមឃុំ ភូមិ ដោយសារមានការណែនាំពីលេខាធិការដ្ឋានបោះឆ្នោតខេត្ត និង នាយខុទ្ទកាល័យ ខេត្ត ដើម្បីជំរុញការងារនេះឱ្យបានលឿន ដោយមិនប្រកាន់និន្នាការនយោបាយដូចដែលលោកស្រី សុភាពលើកឡើងទេ ។ លោក បានសំនូមពរដល់គ្រប់គណបក្សនយោបាយទាំងអស់ សូមចូលរួម និងជួយផ្សព្វផ្សាយ បើមានការងារ ឬផែនការពីស្រុកដាក់ជូន ហើយពាក់ព័ន្ធនឹង រឿងមេភូមិនៅច្រកល្មៀត បានចូលរួមជាភ្នាក់ងារសង្កេតការណ៍បោះឆ្នោត (ដោយលោកបានចូលរួមផ្ទាល់ដែរ) គឺមិនមែនមេភូមិ សាំង យូសុះ ទេ អ្នកដែលចូលជាអ្នកសង្កេតការណ៍ឈ្មោះ ម៉ាត់ លី ។

លោក **គឹម សេង** ជំទប់ទី ២ ឃុំអញ្ចាញរូង មកពីគណបក្សហ៊្វុនស៊ិនប៉ិច លោកបានលើឡើងបញ្ហានានាទាក់ទងនឹងការបោះឆ្នោតដោយសង្ខេបៗទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ការផ្តល់អត្តសញ្ញាណប័ណ្ណ និងប័ណ្ណ ពតិមានអ្នកបោះឆ្នោត តែនៅមានចំណុចមួយដែលនៅខ្វះចន្លោះគឺការដោះស្រាយបញ្ហានានានៅមូលដ្ឋានផ្ទាល់ លោកសំណូមពរទៅ គជប និង អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងមន្ទីរក្រសួងនានាដែលពាក់ព័ន្ធនឹងការងារបោះឆ្នោតថា សូមជួយសំរួលការងារនៅមូលដ្ឋានដោយយើងបានរៀបចំការបោះឆ្នោតច្រើនលើកហើយ តែនៅមិនទាន់មានគណៈកម្មការសំរបសំរួលណានៅមូលដ្ឋានទេ មានតែអញ្ជើញគណបក្សនយោបាយមកប្រជុំតែប៉ុណ្ណោះ ។ ដូច្នេះសូមឱ្យបង្កើតគណៈកម្មការមួយសំរាប់សំរបសំរួលទំនាស់នានាដែលអាចកើតមាននៅមូលដ្ឋាន ដោយត្រូវមានសមាសភាពចំរុះ ដូចជាគណបក្សនយោបាយនានាដែលមាននៅមូលដ្ឋានសុំឱ្យចូលរួមអាចជាការផ្សព្វផ្សាយ ដោះស្រាយ រឺសំរបសំរួលបញ្ហានានាដែលកើតមាន ។ ការផ្តល់ប័ណ្ណពតិមានអ្នកបោះឆ្នោតជូនពលរដ្ឋមានសារៈសំខាន់ណាស់ ដើម្បីចេះប្រើឯកសារណាមួយដែលបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន ធ្វើដូច្នេះការសរសេរឈ្មោះលើកក្រោយនឹងមិនអាចខុសបានទេ ។ លោកសំណូមពរដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គប្រជុំថ្ងៃនេះជួយសំរួលថា រាល់ពេលចុះ យុទ្ធនាការធ្វើអត្រានុកូលដ្ឋាន និងអត្តសញ្ញាណប័ណ្ណ ត្រូវជូនដំណឹងនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដោយមានគណៈកម្មការចំរុះដឹងឮជៀសវាង ការចោទប្រកាន់ថាមិនដឹង ។

**លោក ឱក សេរី សោភក្តិ៍** នៅថ្នាក់ជាតិក៏មានលើកស្នើឱ្យមានគណៈកម្មការដូចនេះដែរ ទាំង ឯ.ឧ ទេព នីថា និង ឯ.ឧ អ៊ឹម សួស្តី បានទទួលយកសំណើនេះ ទៅពិនិត្យ ពិចារណា ទោះមិនទាន់មាននៅក្នុងនីតិវិធី តែ គជប បានចេញផ្សាយសេចក្តីព្រាងនៅថ្ងៃ ១៥ រូបមន្តដែលបានលើកឡើង គឺកំពុងតែសិក្សា ។ សង្ឃឹមថា នៅ ដំណាក់កាលក្រោយៗនឹងមានគណៈកម្មការនេះឡើង ។

លោក **ប៉ុល ទិត្យធានី** ប្រធានគណបក្ស សម រង្ស៊ី ស្រុកកំពង់ត្រឡាច លោកមានប្រសាសន៍ទាក់ទង នឹងការចែកប័ណ្ណពតិមានដល់ពលរដ្ឋ ។ លោកបានតាមដានយ៉ាងដិតដល់ និងមានភស្តុតាងច្បាស់លាស់ អំពីអ្វីដែលទង្វើ ខុសប្រក្រតីរបស់ក្រុមប្រឹក្សាឃុំ និងប្រធានភូមិដែលបានអនុវត្តកន្លងមក លោកសូមសរសើរចំពោះភូមិឃុំទាំងឡាយដែលធ្វើការបានល្អ តែឃុំខ្លះធ្វើ ខុសនីតិវិធី ដូចជាឃុំសែត តាមស្មារតីអង្គប្រជុំនៅសាលាស្រុក ជាមួយលោកស្រី នួន ចាន់នី ថា ត្រូវចាត់ចែងក្រុមប្រឹក្សាឃុំណាម្នាក់ដើម្បីទទួល ការងារចែកប័ណ្ណបោះឆ្នោត ។ តែលោកមេឃុំ មិនអនុវត្តដូច្នោះទេ ទៅប្រគល់ប័ណ្ណពតិមានទៅឱ្យមេភូមិនីមួយៗទៅចែកតែម្តង លោកមិនបានធ្វើ កាលវិភាគសំរាប់បែងចែកការងារនេះទេ ដោយឡែកនៅឃុំកំពង់

ត្រឡាច ដែលចែកប័ណ្ណពីថ្ងៃ ១៤-១៨ សីហា នៅភូមិកំពង់ត្រឡាចក្រោម គាត់ធ្វើ ការងារនេះតែមួយថ្ងៃគត់ ។ ថ្ងៃទី ១៥ លោកមកប្រជុំនៅស្នាក់ការគណបក្សប្រជាជន ម្សិលមិញគ្មានពត៌មានមិនដឹងថាគាត់ទៅណា ។ នេះមិនមែនទុទិដ្ឋិនិយមថាគាត់ចែកតែបក្សពួកនោះទេ ឬទិន្នាការនយោបាយអ្វីទេ ប៉ុន្តែនេះជាចំណុចខ្វះខាត ជាក់ស្តែងលោក វី ដែលនៅទល់មុខកន្លែងចែក ហេតុអ្វី បានជាគេមិនផ្តល់ពត៌មានឱ្យលោក លោក វី ថា មិនដឹង គេមិនបានប្រាប់ឱ្យទៅយកប័ណ្ណពត៌មានទេ ព្រោះនៅទីនោះជាផ្ទះមេក្រុម ១០ របស់ គណបក្សប្រជាជន ។ នៅឃុំអំពិលទឹក លោកស្នើឱ្យមេបក្សឃុំទៅតាមយកប្រក្រតីទិនការងារ រហូតមកដល់ថ្ងៃនេះ នៅមិនទាន់បានទទួលទេនៅ សាលាឃុំ គ្មានអ្នកធ្វើការជួបស្មៀនថាមិនដឹង ។ លោកមិនច្បាស់ទេថាតើនេះជាចរិតនយោបាយ ឬជាចរិតអចេតនាទេ ទាក់ទងនឹងការចែកប័ណ្ណពត៌មាន ដែលលោកបានទទួលមួយដែរ តែខុសថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត នេះជាកំហុសបច្ចេកទេសច្រើនណាស់ ។ តាមការសាកសួរពលរដ្ឋដែល ទទួលបាន ឃើញថាមានត្រឹមត្រូវតិចណាស់ ។

លោកសំណូមពរថា សុំឱ្យ គជប ពន្យាពេលចែកប័ណ្ណ រហូតដល់ថ្ងៃទី ០១ ដែលជាថ្ងៃពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតឡើងវិញ ព្រោះមកដល់ពេលនេះ នៅសល់តែជាង ១០ថ្ងៃទេ នឹងត្រូវបញ្ចប់ការចែកប័ណ្ណនេះ ។ បើស្នើឱ្យពលរដ្ឋទៅសាលាឃុំ គាត់នឹងមិនទៅទេ ឆ្ងាយពីផ្ទះគាត់ ដោយសារជាប់ស្ទូង ដូច្នេះសុំឱ្យមេឃុំ ជំទប់ ធ្វើឱ្យបានល្អ ដូចឃុំចចេស ដែលលោកបានសរសើរ គឺលោកបានមកចែកឱ្យដល់ផ្ទះ ។ សំរាប់យើងជាអ្នកចេះដឹងគ្រាន់តែយកអត្តសញ្ញាណប័ណ្ណទៅផ្ទៀងជាមួយបញ្ជីឈ្មោះអ្នកបោះឆ្នោតជាការស្រេច តែប្រជាពលរដ្ឋមានការពិបាក ។ ចំពោះខាងស្នងការប៉ូលីសទាក់ទិននឹងការធ្វើអត្តសញ្ញាណប័ណ្ណ ដើម្បីកុំឱ្យខុស ត្រូវយកសំបុត្រកំណើតជាគោល ដែលវាក៏ងាយស្រួលដល់ការធ្វើបញ្ជីបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ។

លោក **ម៉ាន ទាំ** សមាជិកក្រុមប្រឹក្សាឃុំឈូកស ស្រុកកំពង់ត្រឡាច លោកសូមជំរាបជូនខាងនគរបាលដែលទទួលបន្ទុកធ្វើសៀវភៅគ្រួសារ តាមពត៌មានពីប្រជាពលរដ្ឋថា លោកយក ២.៥០០០៛ ក្នុងមួយសៀវភៅ គ្រួសារ ធ្វើឱ្យពលរដ្ឋលែងចង់ធ្វើហើយ ព្រោះថ្លៃណាស់សំរាប់ពលរដ្ឋនៅជនបទ សំរាប់ចាស់ៗហើយ មិនមានបញ្ហាអ្វីទេ តែសំរាប់គូស្រករទើប រៀបការថ្មី គាត់ចង់បានសៀវភៅគ្រួសារបែកពីឪពុកម្តាយ ។ លោកខាងប៉ូលីស បានបញ្ជាក់ថា ការធ្វើសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណ ពុំមាន ការយកលុយកាក់អ្វីទេ ដោយសារយើងមានប្រាក់ខែតិចតួចចេះជួយគ្នាបន្តិចបន្តួចទៅតាមសមត្ថភាព ពលរដ្ឋមិនកំណាញ់ទេ តែសុំកុំឱ្យថ្លៃពេក ចុះ មកត្រឹម ៦.០០០៛ ដូចមុនបានទេ ។ ចំពោះការចុះអត្រានុកូលដ្ឋាន និងសៀវភៅគ្រួសារ សរសេរខុសគ្នាខ្លាំងណាស់ ជួនកាលនៅពេលចុះ អត្រានុកូលដ្ឋាន ក្មេងទៅចុះឈ្មោះខ្លួនឯង ភាគច្រើនខុសត្រង់ឆ្នាំកំណើត ។ លោកសូមយល់ស្របនឹងមតិលោកស្រី គី សុភាព ដែលថា ប័ណ្ណពត៌មាន សំខាន់ ។ វាពិតជាសំខាន់មែន បើពលរដ្ឋមិនបានយកចិត្តទុកដាក់ទេនៅពេលដល់ថ្ងៃបញ្ចប់ការចែក ហើយឱ្យពលរដ្ឋទៅយកនៅសាលាឃុំ នឹងមានការពិបាកហើយ លោកក៏បានសួរថា ហេតុអ្វីបានជាមិនប្រើប័ណ្ណបោះឆ្នោតចាស់ ហើយយកសៀវភៅគ្រួសារ អត្រានុកូលដ្ឋាន និងអត្តសញ្ញាណប័ណ្ណ ជំនួសវិញ ដែលហាក់ដូចជាបង្កភាពស្មុគស្មាញដល់ពលរដ្ឋនៅមូលដ្ឋាន ។

**លោក ឱក សេរី សោភក្តិ៍** កិច្ចពិភាក្សាព្រឹកនេះ ហាក់ដូចជាបានលើកបញ្ហាបានគ្រប់ជ្រុងជ្រោយល្មមអស់ហើយ គ្រប់ដំណាក់កាលនៃការបោះឆ្នោត ជាពិសេសលើការចុះឈ្មោះ អ្នកបោះឆ្នោត ប័ណ្ណពត៌មានអ្នកបោះឆ្នោត អត្តសញ្ញាណប័ណ្ណ ការដោះស្រាយនិងទទួលពាក្យបណ្តឹង ដែលសុំឱ្យមានបង្កើតគណៈកម្មការចំរុះសំរាប់ សំរបសំរួលបញ្ហានានាដែលស្នើឡើងដោយតំណាងហ៊ុនស៊ិនប៉ិច ។

**លោកស្រី នួន ចាន់នី** រៀងរាល់ដំណើរការបោះឆ្នោតដែលមាន គជបខ ឬលេខាធិការដ្ឋានរៀបចំការពិនិត្យបញ្ជីឈ្មោះ តែងបានអញ្ជើញតំណាងគណបក្សទាំងអស់ចូលរួម ប្រជុំ មិនចំពោះតែការចូលរួមពិនិត្យបញ្ជីឈ្មោះ និងការរៀបចំ គជបខ នោះទេ ព្រមទាំងបានអញ្ជើញតំណាង

អង្គការសង្គមស៊ីវិលនានាដែលមាន ទីតាំងនៅក្នុងខេត្តផងដែរ ដែលការប្រជុំនោះ ប្រព្រឹត្តទៅរៀងរាល់សប្តាហ៍ ដើម្បីជំរាបជូនពីការងារដែលនឹងត្រូវអនុវត្ត និងការងារដែលបានអនុវត្ត កន្លងមក ។

ក្នុងនោះយើងបានជំរាបជូនអង្គប្រជុំ អំពីការប្រើទំរង់នានា រួចរាល់អស់ហើយ ។ លោកស្រីបានកត់សំគាល់ថា តំណាងគណបក្សខ្លះដែលបានចូលរួម មិនបានបញ្ជូនពតិមាននោះទៅសមាជិកគាត់ទេ ដែលគ្រប់គណបក្សនយោបាយ គួរទទួលស្គាល់ ដូច្នេះនាំឱ្យមានអ្នកអនុវត្តន៍មិនត្រូវតាមការណែនាំ ។ កាលពីបោះឆ្នោតសមាជិកព្រឹទ្ធសភា យើងបានប្រជុំរាល់សប្តាហ៍ និងបានបណ្តុះបណ្តាលរួមគ្នាទាំងតំណាងគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោត ។ ទោះយ៉ាងណាបញ្ហានៅពេលបោះឆ្នោតនៅមានបញ្ហាជានិច្ច ពិសេសលើការរាប់សន្លឹកឆ្នោត ។

ទាក់ទិននឹងការជ្រើសរើសមន្ត្រីបោះឆ្នោត ដែលមានចោទថា មានការយកលុយកាក់ ។ អនុវត្តតាមគោលការណ៍របស់ គជប គជបខ គឺការជ្រើសរើសដោយផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យ ក្របខ័ណ្ឌច្បាស់លាស់ តាមបទបញ្ជា និងច្បាប់បោះឆ្នោតបានកំណត់ ។ បើកើតមានដូច្នេះមែនយើងខ្ញុំនឹងទុកជាបទពិសោធន៍ សំរាប់ធ្វើការរៀបចំការបោះឆ្នោតឆ្នាំ២០០៧ ឱ្យបានល្អ ។ កន្លងមក ក៏ការងារនេះអនុវត្តបាល្អដែរ តែការដែលចោទថាមានការយកលុយកាក់ ខាង គជបខ មិនបានដឹងទេ ។

ហេតុអ្វីបានជាកាតសិស្ស និងកម្មករ មិនអាចយកទៅបោះឆ្នោតបាន? ច្បាប់កំណត់ថា ត្រូវមានប័ណ្ណសំគាល់ផ្លូវការណាមួយក្នុងចំណោម ១០ ប័ណ្ណសំគាល់ផ្លូវការ ទើបពលរដ្ឋអាចបោះឆ្នោតបាន ដូចនៅខ្នងប័ណ្ណពតិមានបញ្ជាក់ជូនដែរ ។ ប័ណ្ណបោះឆ្នោតដែលមានពីមុន ឈប់ប្រើតាំងពីក្រោយការបោះឆ្នោតតំណាងរាស្ត្រ ២០០៣ ដោយការផ្សព្វផ្សាយកាលនោះមិនបានទូលំទូលាយ គ្រប់ការពិនិត្យបញ្ជីឈ្មោះ តែពេលនេះចូលដល់ដំណាក់កាលបោះឆ្នោត ដូច្នេះត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ នៅក្នុងប័ណ្ណពតិមានក៏បញ្ជាក់ដែរថា ប័ណ្ណបោះឆ្នោត ៩៣ ៩៨ ២០០២ ឈប់ប្រើហើយ ។ នេះច្បាប់កំណត់បែបនេះ ។ គជបខ គ្រាន់តែជាអ្នកអនុវត្តតាមច្បាប់ប៉ុណ្ណោះ ។

ការផ្តល់ប័ណ្ណពតិមានអ្នកបោះឆ្នោត គជបខ បានអញ្ជើញគ្រប់គណបក្សនយោបាយទាំងអស់នៅថ្នាក់ខេត្ត និងតំណាងអង្គការសង្គមស៊ីវិលឱ្យចូលរួមផ្សព្វផ្សាយបានដល់សមាជិករបស់ខ្លួនតាមស្រុក ឃុំ ភូមិ ផង ។ ការផ្តល់ប័ណ្ណពតិមានអ្នកបោះឆ្នោត គឺសំរួលដល់ពលរដ្ឋ ឱ្យដឹងពីទិន្នន័យនានារបស់ខ្លួន ដោយសារកន្លងមកថា ពិបាករកឈ្មោះ ការិយាល័យ មិនឃើញ ហើយយើងបានរៀបចំចែកទៅតាមកម្មវិធីបានត្រឹមត្រូវតាមការណែនាំ ដោយមេឃុំ សហការចែកជាមួយមេភូមិ ។

ចំពោះរាល់បណ្តឹងមក គជបខ ចោទថា មានការដោះស្រាយមិនបានត្រឹមត្រូវ លោកស្រីមានមតិថារាល់បណ្តឹងគ្រប់គណបក្សនយោបាយទាំងអស់ គឺ គជបខ ដោះស្រាយបានត្រឹមត្រូវតាមច្បាប់ទាំងអស់ ដោយយកការសំរបសំរួលជាជំហានដំបូង ។ បើ គជបខ ដោះស្រាយមិនបានត្រឹមត្រូវលោកមានសិទ្ធិប្តឹងបន្តដល គជប និងក្រុមប្រឹក្សាធម្មនុញ្ញ ។ ការមិនដោះស្រាយបណ្តឹងលុះត្រាតែបណ្តឹងនោះ ហួសអាជ្ញាធុការ ។

**លោក ឡារី ស្រ្តែន្ទ** នេះជាការលំបាកណាស់ក្នុងការធ្វើសេចក្តីសន្និដ្ឋាន អំពីអ្វីដែលលោក លោកស្រី បានលើកឡើង ប្រកបដោយខ្លឹមសារជ្រាលជ្រៅបំផុត ។ លោកបាន ធ្វើការសង្ខេប បីចំណុច ។

ទី១ ដែលលោក លោកស្រីបានលើកឡើង គឺការចុះឈ្មោះអ្នកបោះឆ្នោត និងការចែកប័ណ្ណពតិមាន បង្ហាញមានការវិវត្តន៍ កាន់តែល្អទៅមុខ តែក៏នៅចំណុចខ្វះខាតនានាដែលត្រូវធ្វើការកែលំអដែរ ។ យើងបានដឹងអំពីការងារនានាជុំវិញការងាររៀបចំបោះឆ្នោត ទទួលបាន នូវការគោរព និងសាទរនានា ចំពោះមន្ត្រីរៀបចំការបោះឆ្នោតថ្នាក់ខេត្ត ស្រុក ឃុំ ភូមិ អាជ្ញាធរនានា ដែលបានសហការ និងខិតខំធ្វើការនេះ ដើម្បីដំណើរការនេះប្រព្រឹត្តទៅបានល្អ ។ ចំនុចមួយទៀតដែលយើងបានលើកឡើងគឺធ្វើយ៉ាងណាដើម្បីឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយគ្មានអំពើហិង្សា ការបំភិតបំភ័យ និងបានជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់គោរពតាមច្បាប់ និងក្រមសីលធម៌ក្នុងការអនុវត្តន៍ ដើម្បីឱ្យការបោះឆ្នោតទាំងនៅថ្នាក់ជាតិ និងមូលដ្ឋាន ប្រព្រឹត្តទៅបានល្អ និងទទួលបានជោគជ័យ ។

ទី២ លោក លោកស្រីបានបារម្ភណ៍ពីការចែកចាយប័ណ្ណតិមានបោះឆ្នោតដល់ពលរដ្ឋ អំពីប្រសិទ្ធិភាព សមភាព និងតម្លាភាពក្នុងការចែកធានាឱ្យសំរេច និងជូនប័ណ្ណនេះបានដល់ពលរដ្ឋយើង ។

ចំណុចចុងក្រោយ ដែលជាទស្សនៈផ្ទាល់ខ្លួន ក្នុងនាមលោកជាជនបរទេសដែលទើបមកធ្វើការនៅកម្ពុជាបានជាង ២ឆ្នាំ ។ ដែលមកពីប្រទេសអូស្ត្រាលី ជាប្រទេសទើបមានអាយុកាលជាង ១០០ឆ្នាំ គឺជាប្រទេសមួយដែលអនុវត្ត និងប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យមួយដ៏រឹងមាំ និងទទួលបាននូវការគោរពពីគ្រប់ភាគីពាក់ព័ន្ធនានា ។ មុននឹងយើងទទួលបាននូវលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំនេះ ទាមទារពេលយូរអង្វែងច្រើនដំណាក់ និងច្រើនទសវត្សរ៍ ។ ជោគជ័យដែលទទួលបាន គឺអាស្រ័យដោយកិច្ចសហការ និងការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធនៅក្នុងប្រទេសអូស្ត្រាលី ពិសេសអ្នកដឹកនាំគណបក្សនយោបាយ អង្គការសង្គមស៊ីវិល អាជ្ញាធរ សហគមន៍ សារពតិមាន និងពលរដ្ឋទាំងអស់ ដើម្បីជំរុញដំណើរការកសាងលទ្ធិប្រជាធិបតេយ្យមួយដ៏ខ្លាំងក្លា ។ លោកលើកឡើងពីបទពិសោធន៍នេះ ដើម្បីរួមចំណែកបង្ហាញជូនលោក លោកស្រី គឺការកសាងលទ្ធិប្រជាធិបតេយ្យ និងសូមកោតសរសើរ ចំពោះការចូលរួមរបស់លោក លោកស្រី ដែលបានលើកឡើងនូវមតិនានា ជុំវិញការងារបោះឆ្នោត ដើម្បីជាដំណើរមួយជំរុញឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងដើម្បីកែលំអដំណើរការរៀបចំការបោះឆ្នោត ឱ្យទទួលបានជោគជ័យល្អប្រសើរ ។

នៅទីបញ្ចប់លោកបានអរគុណដល់ឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំងដែលបានអនុញ្ញាតឱ្យ វិបសអ រៀបចំកិច្ចប្រជុំនេះឡើង និង UNDP ដែលឧបត្ថម្ភយន្តការនេះ តំណាង SIDA លោក ឱក សេរី សោភក្តិ៍ ដែលបានសំរបសំរួលយន្តការនេះដ៏មានប្រសិទ្ធិភាព និងការចូលរួមពីសំណាក់លោក លោកស្រី ។

**លោក Douglas Gardner** ជាថ្មីម្តងទៀត សូមអរគុណ និងសូមបំពេញបន្ថែមនូវអ្វីដែលលោក ឡារី បានជំរាបជូន ។ ក្នុងនាមតំណាង UNDP និង SIDA ដែលមកចូលរួម នាព្រឹកនេះ លោកបានចាប់អារម្មណ៍ថា លោក លោកស្រីដែលមានវត្តមាននៅទីនេះ បានបញ្ចេញយោបល់គ្រប់ៗគ្នា ដោយលើកឡើងបញ្ហានានា និង រិះរកដំណោះស្រាយរួមគ្នា ។ សកម្មភាពនេះបានបង្ហាញពីដំណើរការប្រជាធិបតេយ្យ មិនថាតែនៅក្នុងកិច្ចប្រជុំខប់សែល នេះទេ អាចមានដំណើរការ បែបនេះ ក្នុងកិច្ចប្រជុំផ្សេងៗទៀតដែរ ។ នេះជាលើកទី ១ ហើយដែលមានឱកាសចូលរួមជាមួយយន្តការខប់សែល និងបានឆន្ទៈចូលរួមយ៉ាងខ្លាំង ក្លាពីសំណាក់លោក លោស្រី ដោយបានលើកឡើងនូវបញ្ហានានា ដើម្បីរកដំណោះស្រាយជាមួយគ្នាចំពោះមុខគ្នា ដោយស្មោះត្រង់ នេះជាចំណុចល្អ បំផុត ពិសេសសូមកោតសរសើរលោកស្រី ប្រធាន គជបខ ដែលបានលើកឡើងចំណុចនានា និងឆ្លើយតបរាល់សំណួរនានាបានយ៉ាងក្បោះក្បាយ និង យ៉ាងក្លាហាន ។ សូមជូនពរបងប្អូនប្រមូលផលស្រូវបានល្អ ហើយកូនចៅលោក លោកស្រីនឹងបាចូលរៀននៅសាលារៀនល្អ និងមានគុណភាព និងសូមជូនពរលោក លោកស្រី មានសុខភាពល្អ ។ នៅថ្ងៃ ១ មេសា ២០០៧ នឹងមានការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្ឃឹមថា ទាំងបុរស ស្ត្រី នឹង ចូលរួម ដើម្បីជ្រើសរើសតំណាងនៅមូលដ្ឋានឱ្យបានជាស្ថាពរ ។

**លោក ឱក សេរី សោភក្តិ៍** យើងនៅចាំមិនភ្លេចទេថា តាំងពីដើមឡើយ លោក Douglas Gardner មានទស្សនៈវិស័យបែបនេះរហូតមក ដើម្បីឱ្យមានការចូលរួមពីប្រជាពលរដ្ឋ សង្គមស៊ីវិល និស្សិត គណបក្សនយោបាយ ក្នុងក្របខ័ណ្ឌអភិបាលកិច្ច និងប្រជាធិបតេយ្យ ។ លោកមានសេចក្តីរីករាយណាស់ ដោយមានវត្តមានខាង UNDP, SIDA ។ នេះជាមោទនភាពណាស់ ដែលបានឃើញយើងចេះទាស់គ្នា ដោយចំហ ត្រង់ទៅត្រង់មក និងទទួលយកអនុសាសន៍ពីគ្នាទៅវិញទៅ មក ដើម្បីទៅស្ថាបនាប្រជាធិបតេយ្យ ។ បើយើងចេះទាស់ប្រកបដោយសីលធម៌ ដោយវប្បធម៌ទំនុកចិត្តបែបនេះតទៅទៀត គ្មានអ្វីមួយដែលថ្នាក់ ដឹកនាំប្រទេសកម្ពុជា និងមិត្តកម្ពុជា ធ្វើមិនបាននោះទេ នឹងអាចធ្វើបាន ។ នេះជាមរតកដែលនឹងបន្សល់ទុកដល់យុវជនជំនាន់ក្រោយឱ្យលែងរងវេទនាដូច ជំនាន់យើងទាំងអស់គ្នាឆ្លងកាត់សង្គ្រាមវេទនា ខ្លោចផ្សារ ។ ជាចុងបញ្ចប់ សូមឱ្យគុណបុណ្យព្រះរតន ត្រៃយ៏ ជួយថែរក្សា លោក លោកស្រីទាំងអស់ ឱ្យប្រកបតែសុខភាពបរិបូណ៌ និងប្រមូលផលស្រូវបានច្រើន

និងសូមឱ្យស្មារតីនៃសហប្រតិបត្តិការ បានល្អ ដើម្បីរៀបចំការបោះឆ្នោតឆ្នាំ២០០៧ ២០០៨ ក្នុងបរិយាកាសសន្តិភាព ប្រតិបត្តិការគ្នា យោគយល់គ្នា ។